**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ** :០៣៥/៣ ន

# សារាចរណែនាំ

# ស្តីពី

# ការរៀបចំផែនការយុទ្ធសាស្ត្រថវិកាឆ្នាំ ២០១៨-២០២០

## ១. សេចក្តីផ្តើម

មាត្រា ៣៩ នៃច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ បានចែងថា ប្រតិទិនសម្រាប់ការរៀបចំសេចក្តីព្រាងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងប្រចាំឆ្នាំ ចែកជា ៣ ដំណាក់កាល÷ **ដំណាក់កាលទី ១** គឺការរៀបចំផែនការយុទ្ធសាស្ត្រថវិកា ចាប់ពីខែ មីនា ដល់ខែ ឧសភា, **ដំណាក់កាលទី ២** គឺការរៀបចំកញ្ចប់ថវិកា ចាប់ពីខែ មិថុនា ដល់ខែ កញ្ញា និង**ដំណាក់កាលទី ៣** គឺការអនុម័តថវិកា ចាប់ពីខែ តុលា ដល់ខែ ធ្នូ។ សម្រាប់ដំណាក់កាលទី ១ នេះ រាជរដ្ឋាភិបាល តាមរយៈក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ បានដាក់ចេញរួចហើយនូវក្របខ័ណ្ឌគោលនយោបាយម៉ាក្រូសេដ្ឋកិច្ច និងគោលនយោបាយហិរញ្ញវត្ថុសាធារណៈ សម្រាប់ការរៀបចំសេចក្តីព្រាងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០១៨ ដើម្បីឱ្យក្រសួង-ស្ថាប័ននីមួយៗ មានមូលដ្ឋានសម្រាប់ការរៀបចំផែនការយុទ្ធសាស្ត្រថវិកាឆ្នាំ ២០១៨-២០២០ និងការលើកគម្រោងថវិកាប្រចាំឆ្នាំ ២០១៨។ នៅជំហានបន្ទាប់នៃដំណាក់កាលទី ១ នេះ រាជរដ្ឋាភិបាលត្រូវដាក់ចេញសារាចរណែនាំស្តីពីការរៀបចំផែនការយុទ្ធសាស្ត្រថវិកាឆ្នាំ ២០១៨-២០២០ ដើម្បីផ្តល់គោលការណ៍ណែនាំថ្មីៗ និងមគ្គុទ្ទេសបច្ចេកទេសគន្លឹះ សម្រាប់ជាជំនួយដល់គ្រប់ក្រសួង-ស្ថាប័ន ក្នុងការធ្វើបច្ចុប្បន្នភាពផែនការយុទ្ធសាស្ត្រថវិកា ដែលជាផែនការថវិការយៈពេល បីឆ្នាំរំកិល ដែលក្រសួង-ស្ថាប័ន មន្ទីរជំនាញរាជធានី-ខេត្ត និងគ្រឹះស្ថានសាធារណៈរដ្ឋបាល ដែលស្ថិតក្រោមក្រសួង-ស្ថាប័ននីមួយៗ ត្រូវរៀបចំនៅដំណាក់កាលទីមួយ នៃដំណើរការរៀបចំគម្រោងថវិកាប្រចាំឆ្នាំ។ ដោយឡែក ចំពោះការរៀបចំផែនការយុទ្ធសាស្ត្រថវិកាសម្រាប់រដ្ឋបាលថ្នាក់ក្រោមជាតិ នឹងមានសារាចរណែនាំដោយឡែកមួយផ្សេងទៀត ស្របតាមច្បាប់ស្តីពីរបបហិរញ្ញវត្ថុ និងការគ្រប់គ្រងទ្រព្យសម្បត្តិរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ដែលត្រូវបានប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/ ០៦១១/០១១ ចុះថ្ងៃទី ១៧ ខែ មិថុនា ឆ្នាំ ២០១១។

ផែនការយុទ្ធសាស្ត្រថវិកា គឺជាឧបករណ៍មួយដ៏សំខាន់សម្រាប់÷ (១)-ផ្សារភ្ជាប់ថវិកាទៅនឹងគោលនយោបាយរបស់ក្រសួង-ស្ថាប័ន និងគោលនយោបាយរបស់រាជរដ្ឋាភិបាល, (២)-បង្កើនវិចារណកម្មអាទិភាពចំណាយឱ្យកាន់តែឆ្លើយតបទៅនឹងគោលនយោបាយរបស់ក្រសួង-ស្ថាប័ន, (៣)-ធានានិរន្តរភាពនៃការអនុវត្តកម្មវិធីរបស់ក្រសួង-

ស្ថាប័ន ដើម្បីសម្រេចគោលបំណងគោលនយោបាយដែលបានដាក់ចេញ (៤)-ជាមូលដ្ឋានសម្រាប់ពន្យល់ និងបង្ហាញសេចក្តីសំអាងអំពីតម្រូវការថវិកាសម្រាប់អនុវត្តគោលនយោបាយ និង (៥)-ជាមូលដ្ឋានសម្រាប់ការរៀបចំនិងវិភាជថវិកាប្រចាំឆ្នាំឱ្យចំគោលដៅអាទិភាព។ ដូច្នេះ ផែនការយុទ្ធសាស្ត្រថវិកា ត្រូវតែឆ្លុះបញ្ចាំងឱ្យឃើញច្បាស់អំពីគោលបំណងគោលនយោបាយរបស់ក្រសួង-ស្ថាប័នសាមីនីមួយៗ, អំពីកម្មវិធីយ៉ាងច្បាស់លាស់, អំពីសូចនាករ និងគោលដៅសូចនាករសម្រាប់វាស់វែងលទ្ធផលនៃការអនុវត្តកម្មវិធី សមស្របនឹងទំហំថវិកា និងលទ្ធភាពថវិកាដែលមាន ដើម្បីចូលរួមចំណែកសម្រេចគោលនយោបាយរបស់រាជរដ្ឋាភិបាលដែលបានដាក់ចេញក្នុង "**យុទ្ធសាស្ត្រចតុកោណ-ដំណាក់កាលទី ៣**" និងផែនការសកម្មភាពដែលបានដាក់ចេញក្នុង "**ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ២០១៤-២០១៨**"។ ក្នុងន័យនេះ ក្រសួង-ស្ថាប័នមួយ ត្រូវមានផែនការយុទ្ធសាស្ត្រថវិការួមមួយ ដែលគ្របដណ្តប់ទាំងថវិការដ្ឋបាលកណ្តាល, ថវិកាមន្ទីរជំនាញរាជធានី-ខេត្ត និងថវិការបស់គ្រឹះស្ថានសាធារណៈរដ្ឋបាលដែលស្ថិតក្រោមឱវាទក្រសួង-ស្ថាប័ននោះ។

ទន្ទឹមនេះ ភាពគ្រប់ជ្រុងជ្រោយនៃថវិកា តាមរយៈសមាហរណកម្មពិតប្រាកដរវាងថវិកាចរន្ត និងថវិកាមូលធន ព្រមទាំងរវាងថវិកាជាតិ និងថវិកាហិរញ្ញប្បទានសហប្រតិបត្តិការ គឺជាកត្តាគន្លឹះមិនអាចខ្វះបាន ដើម្បីធ្វើឱ្យផែនការយុទ្ធសាស្ត្រថវិកាមានគុណភាព និងអាចក្លាយជាឧបករណ៍ និងយន្តការជាក់ស្តែងសម្រាប់ការលើកកម្ពស់ប្រសិទ្ធភាព និងភាពស័ក្តិសិទ្ធិសម្រាប់វិភាជ និងគ្រប់គ្រងថវិកាប្រចាំឆ្នាំ។ ក្នុងន័យនេះ *ក្រសួង-ស្ថាប័ននីមួយៗ ចាំបាច់ត្រូវជំរុញ និងលើកទឹកចិត្តដល់ក្រុមការងារថវិការបស់ខ្លួន ដែលមានសមាសភាពមកពីនាយកដ្ឋានថវិកា/ហិរញ្ញវត្ថុ/និងគណនេយ្យ នាយកដ្ឋានផែនការ អង្គភាពជំនាញ និងអង្គភាពគ្រប់គ្រងគម្រោង ឱ្យដំណើរការដោយសកម្ម និងប្រកបដោយការទទួលខុសត្រូវខ្ពស់។* **ក្រុមការងារថវិកា** ត្រូវខិតខំធានាឱ្យប្រាកដថាទាំងធនធាន និងទាំងសកម្មភាពការងារទាំងអស់របស់ក្រសួង-ស្ថាប័នខ្លួន ត្រូវបានដាក់បញ្ចូល ឬ ឆ្លុះបញ្ចាំងនៅក្នុងផែនការយុទ្ធសាស្ត្រថវិកា សំដៅធានាថាថវិកាត្រូវបានវិភាជត្រង់ទៅចំសកម្មភាព និងចំសេចក្តីត្រូវការយ៉ាងពិតប្រាកដ ព្រមទាំងធានាបាននូវតុល្យភាពនៃការវិភាជថវិកា ហើយឆ្លើយតបបានជាអតិបរមាទៅនឹងគោលបំណងគោលនយោបាយ និងរវាងកម្មវិធី ដែលបានរៀបចំនៅក្នុងផែនការយុទ្ធសាស្ត្រថវិកា។

ជារួម ផែនការយុទ្ធសាស្ត្រថវិកា គឺជាឧបករណ៍មួយយ៉ាងសំខាន់ សម្រាប់ភាពជោគជ័យនៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈដំណាក់កាលទី ៣ គឺ **ការផ្សារភ្ជាប់ថវិកាទៅនឹងគោលនយោបាយ (២០១៦-២០២០)** ដែលត្រូវបានប្រកាសដាក់ឱ្យអនុវត្តជាផ្លូវការដោយ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា នៅថ្ងៃទី ២១ ខែ មីនា ឆ្នាំ ២០១៦។ ថ្វីត្បិតការរៀបចំផែនការយុទ្ធសាស្ត្រថវិកា ត្រូវបានកែលម្អជាលំដាប់ចាប់តាំងពីត្រូវបានដាក់ឱ្យអនុវត្តនៅឆ្នាំ ២០០៨ ប៉ុន្តែ គុណភាព និងប្រសិទ្ធភាពនៃការរៀបចំផែនការយុទ្ធសាស្ត្រថវិកា មិនទាន់ឈានដល់កម្រិតដែលរាជរដ្ឋាភិបាលចង់បាននៅឡើយ។ ដូច្នេះ ក្រសួង-ស្ថាប័ននីមួយៗ ចាំបាច់ត្រូវកែលម្អគុណភាពផែនការយុទ្ធសាស្ត្រថវិកាឱ្យកាន់តែល្អប្រសើរ ស្របតាមគោលការណ៍ណែនាំស្តីពីការរៀបចំផែនការយុទ្ធសាស្ត្រថវិការបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ, ព្រមទាំងស្មារតី និង

លទ្ធផលនៃការចរចាថវិកាឆ្នាំ ២០១៧ កន្លងទៅ, និងការណែនាំបន្ថែមតាមរយៈសារាចរណែនាំប្រចាំឆ្នាំនេះ ជាពិសេសការគ្រោងវិភាជចំណាយតាមវិស័យនៃចំណាយចរន្តថវិកាថ្នាក់ជាតិ ដូចមានកំណត់នៅក្នុងក្របខ័ណ្ឌគោលនយោបាយហិរញ្ញវត្ថុសាធារណៈ (ផ្នែក **២.២**) ខាងក្រោមនេះ។ *ទន្ទឹមនេះ ដើម្បីលើកកម្ពស់គុណភាពផែនការយុទ្ធសាស្ត្រថវិកាឱ្យកាន់តែល្អប្រសើរ គ្រប់ក្រសួង-ស្ថាប័នចាំបាច់ត្រូវរៀបចំឱ្យមានយន្តការសម្របសម្រួលផ្ទៃក្នុងលើកិច្ចការនេះឱ្យបានច្បាស់លាស់បន្ថែមទៀត អំពីតួនាទីរបស់អគ្គនាយកដ្ឋាន/នាយកដ្ឋានពាក់ព័ន្ធ ព្រមទាំងអាចដាក់ចេញជាគោលការណ៍ណែនាំផ្ទៃក្នុង ស្តីពីការរៀបចំផែនការយុទ្ធសាស្ត្រថវិកា ក៏ដូចជាគោលការណ៍ណែនាំផ្ទៃក្នុងសម្រាប់ការរៀបចំថវិកាប្រចាំឆ្នាំផងដែរ ជាពិសេស សម្រាប់ក្រសួង-ស្ថាប័នដែលមិនទាន់បានបង្កើតនូវយន្តការនេះ ឬ ក៏បានបង្កើតរួចហើយ តែដំណើរការគ្មានប្រសិទ្ធភាព។ ជាមួយគ្នានេះដែរ ក្រសួង-ស្ថាប័ននីមួយៗ និង ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវផ្តល់កិច្ចសហការល្អទៅវិញទៅមក ដោយអនុញ្ញាតឱ្យ**ក្រុមការងារថវិកា**តាមក្រសួង-ស្ថាប័នសាមី មានភាពជាម្ចាស់ក្នុងការធ្វើការងារជាមួយមន្ត្រីជំនាញថវិកានៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដើម្បីពិនិត្យឡើងវិញ និងកែលម្អរចនាសម្ព័ន្ធកម្មវិធី និងសូចនាករសមិទ្ធកម្មតាមកម្រិតនៃរចនាសម្ព័ន្ធកម្មវិធីនីមួយៗ ក្នុងគោលបំណងដើម្បីបង្កើនគុណភាពនៃការរៀបចំផែនការយុទ្ធសាស្ត្រថវិកា ក៏ដូចជាប្រសិទ្ធភាពក្នុងការរៀបចំថវិកាប្រចាំឆ្នាំ។*

ស្របតាម **"ទិសដៅជាយុទ្ធសាស្ត្រនៃការកែទម្រង់ប្រព័ន្ធថវិកានៅកម្ពុជា ២០១៣-២០២០"** ដែលជាទិសដៅនៃការផ្លាស់ប្តូរប្រព័ន្ធគ្រប់គ្រងថវិកាជាជំហានៗពីការផ្តោតលើធាតុចូល និងមជ្ឈការ ឆ្ពោះទៅរកប្រព័ន្ធថវិកាផ្តោតលើលទ្ធផលឬសមិទ្ធកម្ម និងវិមជ្ឈការ ក្រសួង-ស្ថាប័នចំនួន ៣ ចុងក្រោយ រួមមាន÷ ទីស្តីការគណៈរដ្ឋមន្ត្រី, ក្រសួងការពារជាតិ និងក្រសួងមហាផ្ទៃ នឹងត្រូវបានដាក់ឱ្យអនុវត្តថវិកាកម្មវិធីពេញលេញ និង អង្គភាពថវិកា ចាប់ពីឆ្នាំ២០១៨ ហើយដែលត្រូវចាប់ផ្តើមរៀបចំថវិកាកម្មវិធីនៅក្នុងឆ្នាំ២០១៧ ស្របតាមប្រតិទិន នៃការរៀបចំថវិកាប្រចាំឆ្នាំ ដូចក្រសួង-ស្ថាប័នចំនួន ៣៦ ដែលបាននិងកំពុងអនុវត្តថវិកាកម្មវិធីពេញលេញក្នុងឆ្នាំ ២០១៧ នេះ។ ប្រការនេះបានធ្វើឱ្យយុទ្ធសាស្ត្រនៃការពង្រីកការដាក់អនុវត្តថវិកាកម្មវិធីពេញលេញនៅគ្រប់ក្រសួង-ស្ថាប័នថ្នាក់ជាតិ នៅត្រឹមឆ្នាំ ២០១៨ សម្រេចគោលដៅតាមការគ្រោងទុក។

ស្របតាមទស្សនទាននៃការគ្រប់គ្រងថវិកាឆ្ពោះទៅរកលទ្ធផល/សមិទ្ធកម្ម សិទ្ធិអំណាចក្នុងការគ្រប់-គ្រងថវិកា និងលើការអនុវត្តថវិកា ត្រូវបានផ្ទេរជាបណ្តើរៗពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុទៅក្រសួង-ស្ថាប័នសាមី ចំណែកឯសិទ្ធិអំណាចនៃការទទួលខុសត្រូវលើការគ្រប់គ្រង និងអនុវត្តថវិកាផ្ទៃក្នុងក្រសួង-ស្ថាប័ននីមួយៗ ក៏ត្រូវផ្ទេរជាបណ្តើរៗដែរ ពីអគ្គនាយកដ្ឋាន/នាយកដ្ឋានហិរញ្ញវត្ថុ/គណនេយ្យរបស់ក្រសួង-ស្ថាប័ន ទៅអង្គភាពថវិកាផ្ទៃក្នុងក្រសួង-ស្ថាប័ន។ ក្នុងន័យនេះ គ្រប់ក្រសួង-ស្ថាប័នទាំងអស់ កាន់តែមានភាពចាំបាច់បំផុតក្នុងការរៀបចំផែនការយុទ្ធសាស្ត្រថវិកាប្រកបដោយគុណភាព។

ដើម្បីជួយដល់ក្រសួង-ស្ថាប័ន មានមូលដ្ឋានក្នុងការរៀបចំផែនការយុទ្ធសាស្ត្រថវិកាឆ្នាំ ២០១៨-២០២០ ឱ្យកាន់តែមានប្រសិទ្ធភាព និងមានភាពជាក់ស្តែង រាជរដ្ឋាភិបាលសូមធ្វើការណែនាំដល់គ្រប់ក្រសួង-ស្ថាប័ន ដូចខាងក្រោម÷

## ២-ក្របខ័ណ្ឌគោលនយោបាយម៉ាក្រូសេដ្ឋកិច្ច និង គោលនយោបាយហិរញ្ញវត្ថុសាធារណៈ

ក្របខ័ណ្ឌគោលនយោបាយម៉ាក្រូសេដ្ឋកិច្ច និងគោលនយោបាយហិរញ្ញវត្ថុសាធារណៈ សម្រាប់ការរៀបចំសេចក្តីព្រាងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០១៨ បានផ្តល់ទស្សនៈវិស័យទូលំទូលាយនៃការអភិវឌ្ឍសេដ្ឋកិច្ច និងកំណត់ពីការរំពឹងទុកផ្នែកគោលនយោបាយ ដែលរាជរដ្ឋាភិបាលមានលទ្ធភាពអាចនឹងសម្រេចបាន ហើយតាមរយៈនេះ បង្កើតបានជាលំហថវិការួម សម្រាប់ក្រសួង-ស្ថាប័នពាក់ព័ន្ធ អាចកំណត់អាទិភាពសកម្មភាពការងារសម្រាប់រយៈពេលខ្លី និងមធ្យមរបស់ខ្លួន។ ទន្ទឹមនេះ ក្របខ័ណ្ឌគោលនយោបាយម៉ាក្រូសេដ្ឋកិច្ច និងគោលនយោបាយហិរញ្ញវត្ថុសាធារណៈ ក៏កំណត់អំពីលទ្ធភាពផ្នែកធនធាន និងអាទិភាពគោលនយោបាយចម្បងៗ ដើម្បីសម្រេចគោលដៅរួមរបស់រាជរដ្ឋាភិបាល។ ដូចនេះអាចនិយាយបានថា នៅក្នុងដំណើរការនៃការរៀបចំផែនការថវិកា ការកំណត់ក្របខ័ណ្ឌគោលនយោបាយម៉ាក្រូសេដ្ឋកិច្ច និងគោលនយោបាយហិរញ្ញវត្ថុសាធារណៈ គឺជាយន្តការពីលើចុះក្រោម ចំណែកឯការរៀបចំផែនការយុទ្ធសាស្ត្រថវិកា គឺជាយន្តការពីក្រោមឡើងលើ។ យន្តការទាំងពីរនេះ គឺមានភាពចាំបាច់មិនអាចខ្វះបាន ដើម្បីធានាប្រសិទ្ធភាព និងភាពប្រាកដប្រជា អំពីលទ្ធភាពថវិកា និងការរៀបចំថវិកា។

ក្នុងន័យនេះ ដោយផ្អែកលើមូលដ្ឋាននៃ **"យុទ្ធសាស្ត្រចតុកោណ-ដំណាក់កាលទី៣"** និង **ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ២០១៤-២០១៨** រាជរដ្ឋាភិបាលសូមគូសរំលេចនូវខ្លឹមសារស្នូលនៃក្របខ័ណ្ឌគោលនយោបាយម៉ាក្រូ-សេដ្ឋកិច្ច និងគោលនយោបាយហិរញ្ញវត្ថុសាធារណៈ ដែលត្រូវបានរៀបចំដូចខាងក្រោម÷

### ២.១-ក្របខ័ណ្ឌគោលនយោបាយម៉ាក្រូសេដ្ឋកិច្ច

ផ្អែកលើចលនការកំណើនសេដ្ឋកិច្ចខ្ពស់របស់កម្ពុជានៃឆ្នាំកន្លងមក និងភាពនៅតែល្អប្រសើរនៃស្ថានភាពសេដ្ឋកិច្ចក្នុងតំបន់ និងពិភពលោក ព្រមទាំងសកម្មភាពសេដ្ឋកិច្ចនៅតែរស់រវើកនៅដើមឆ្នាំនេះ កំណើនសេដ្ឋកិច្ចឆ្នាំ ២០១៧ ត្រូវបានព្យាករថា អាចសម្រេចបានក្នុងរង្វង់ ៧% តាមការគ្រោងទុកដូចដែលបានដាក់នៅក្នុងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០១៧ ។ ចំពោះកំណើនសេដ្ឋកិច្ចសម្រាប់ឆ្នាំ ២០១៨ ខាងមុខនេះវិញ, តាមការព្យាករបឋម សេដ្ឋកិច្ចកម្ពុជាត្រូវបានរំពឹងថានឹងនៅបន្តកំណើនរឹងមាំក្នុងរង្វង់ ៧%។ កំណើននេះ ត្រូវបានគាំទ្រដោយកំណើននៃវិស័យកសិកម្មប្រមាណ ២,០% និងកំណើនវិស័យឧស្សាហកម្មប្រមាណ ១០,១% ដែលវិស័យនេះគាំទ្រដោយវិស័យកាត់ដេរ, និងសំណង់ ជាពិសេសវិស័យផលិតកម្មមិនមែនកាត់ដេរ ក្នុងនោះ វិស័យកាត់ដេរអាចមានកំណើនប្រមាណ ៨,០% និងវិស័យសំណង់អាចសម្រេចបានប្រមាណ ១២,៤% ព្រមទាំងកំណើនវិស័យសេវាកម្មដែលអាចនឹងសម្រេចបានក្នុងរង្វង់ ៦,៧%។

អត្រាអតិផរណាមធ្យមប្រចាំឆ្នាំ នៅឆ្នាំ ២០១៧ តាមការព្យាករ នឹងស្ថិតក្នុងកម្រិត ៣,៨% គឺខ្ពស់ជាងការព្យាករ ដែលបានដាក់នៅក្នុងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០១៧ ប៉ុន្តែ អាចនឹងថយចុះមកត្រឹម ៣,៥% វិញ នៅឆ្នាំ ២០១៨។ អត្រាប្តូរប្រាក់នៅឆ្នាំ ២០១៧ ត្រូវបានរំពឹងថានឹងមានស្ថិរភាព ដែលមានតម្លៃជាមធ្យម ៤ ០៣៧ រៀលក្នុង ១ ដុល្លារអាមេរិក គឺទាបជាងការព្យាករដែលបានដាក់ក្នុងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០១៧។ ទន្ទឹមនេះ តាមការព្យាករ នៅឆ្នាំ ២០១៨ អត្រាប្តូរប្រាក់ជាមធ្យមប្រចាំឆ្នាំនឹងនៅតែមានតម្លៃ ៤ ០៣៧ រៀលក្នុង ១ ដុល្លារអាមេរិក ដោយសារកំណើនសេដ្ឋកិច្ចខ្ពស់របស់កម្ពុជា និងប្រសិទ្ធភាពក្នុងការបន្តអនុវត្តគោលនយោបាយគ្រប់គ្រងសាច់ប្រាក់ក្នុងវិស័យហិរញ្ញវត្ថុសាធារណៈ និងគោលនយោបាយរូបិយវត្ថុបានល្អ។

ឱនភាពគណនីចរន្តនៅឆ្នាំ ២០១៧ តាមការប៉ាន់ស្មាននឹងមានកម្រិត ៧,៩% នៃ ផ.ស.ស. គឺមានការកើនឡើងបន្តិច បើធៀបនឹងឆ្នាំ ២០១៦ ដែលមានកម្រិត ៧,៦% នៃ ផ.ស.ស.។ ទន្ទឹមនេះ តាមការព្យាករឱនភាពគណនីចរន្ត នឹងកើនឡើងបន្តិចទៀតទៅដល់ ៨,៥% នៃផ.ស.ស. នៅឆ្នាំ ២០១៨។ និន្នាការនៃការកើនឡើងឱនភាពគណនីចរន្ត គឺដោយសារការរំពឹងទុកអំពីកំណើនយឺតបន្តិចនៃការនាំចេញ ខណៈឆ្នាំ ២០១៨ ជាឆ្នាំបោះឆ្នោតសកល ហើយការនាំចូលត្រូវបានរំពឹងថា នឹងនៅតែកើនឡើងស្របគ្នាទៅនឹងនិន្នាការកើនឡើងជាបន្តបន្ទាប់នៃផលិតកម្មក្នុងស្រុកដើម្បីបម្រើឱ្យការប្រើប្រាស់ក្នុងស្រុក ដែលរួមចំណែកកាន់តែធំក្នុងការទ្រទ្រង់កំណើនសេដ្ឋកិច្ចជាតិ។ នៅឆ្នាំ ២០១៧ ទុនបម្រុងនឹងមានទំហំ ៧ ៥៣៨ លានដុល្លារអាមេរិក និង នៅឆ្នាំ ២០១៨ អាចកើនឡើងរហូតដល់ ៧ ៨៥៣ លានដុល្លារអាមេរិក ដែលធានាការនាំចូលប្រមាណជាង ៥,៥ ខែ។

**២.២ ក្របខ័ណ្ឌគោលនយោបាយហិរញ្ញវត្ថុសាធារណៈ**

ដើម្បីសម្រេចបានតាមគោលដៅក្របខ័ណ្ឌគោលនយោបាយម៉ាក្រូសេដ្ឋកិច្ចខាងលើ រាជរដ្ឋាភិបាលបានកំណត់គោលដៅសូចនាករហិរញ្ញវត្ថុសាធារណៈសម្រាប់ឆ្នាំ ២០១៨ ដូចខាងក្រោម÷

- ធានាកំណើនចំណូលចរន្ត ដើម្បីឈានទៅសម្រេចឱ្យបាន ១៨,៦០% នៃ ផ.ស.ស. នៅ ២០១៨ (ធៀបនឹងគោលដៅដែលបានកំណត់នៅក្នុងយុទ្ធសាស្ត្រកៀរគរចំណូលរយៈពេលមធ្យម ២០១៤-២០១៨ ត្រឹមតែ ១៧,៣៥% នៃ ផ.ស.ស. នៅក្នុងឆ្នាំ ២០១៨) ក្នុងនោះ គម្រោងសម្រាប់ថ្នាក់ជាតិ គឺ ១៧,៦៦% នៃ ផ.ស.ស. និងគម្រោងសម្រាប់ថ្នាក់ក្រោមជាតិគឺ ០,៩៤% នៃ ផ.ស.ស.។ ចំណូលពីអគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា គ្រោងសម្រេចឱ្យបាន ៨,៤១% នៃផ.ស.ស., ចំណូលពីអគ្គនាយកដ្ឋានពន្ធដារគ្រោងសម្រេចឱ្យបាន ៧,៦៩% នៃផ.ស.ស. (ក្នុងនោះចំណូលពន្ធដារថ្នាក់ជាតិ គ្រោងសម្រេចឱ្យបាន ៦,៨១% នៃផ.ស.ស. និងចំណូលពន្ធដារថ្នាក់ក្រោមជាតិ គ្រោងសម្រេចឱ្យបាន ០,៨៨% នៃផ.ស.ស.) និងចំណូលមិនមែនសារពើពន្ធត្រូវគ្រោងសម្រេចឱ្យបាន ២,៥០% នៃ ផ.ស.ស.។ ឈរលើមូលដ្ឋាននេះ ចំណូលក្នុងប្រទេសថវិការដ្ឋសម្រាប់ឆ្នាំ ២០១៨ គ្រោងសម្រេចឱ្យបាន ១៨,៧៨% នៃផ.ស.ស.។

- ចំណាយសរុបថវិការដ្ឋនៅឆ្នាំ ២០១៨ នឹងកំណត់ក្នុងរង្វង់ ២៤,៦៨% នៃ ផ.ស.ស. ដែលក្នុងនោះ គម្រោងចំណាយសម្រាប់រដ្ឋបាលថ្នាក់ជាតិមាន ២៣,៧៤% នៃផ.ស.ស. និងគម្រោងចំណាយសម្រាប់រដ្ឋបាលថ្នាក់ក្រោមជាតិមាន ១,៦៨% នៃផ.ស.ស. (ដោយគិតបញ្ចូលទាំងឧបត្ថម្ភធនដល់ថ្នាក់ក្រោមជាតិចំនួន ០,៧៥% នៃផ.ស.ស.)។ ចំណាយចរន្តថវិការដ្ឋត្រូវគ្រោងក្នុងកម្រិត ១៥,៦៨% នៃផ.ស.ស ដែលគម្រោងចំណាយបន្ទុកបុគ្គលិក មានប្រមាណ ៥៣,៧% នៃចំណាយចរន្តថវិការដ្ឋ ឬស្មើប្រមាណ ៨,៤២% នៃផ.ស.ស. ដោយផ្តោតអាទិភាពទៅលើការបង្កើនបៀវត្សសម្រាប់មន្ត្រីរាជការ និងកងកម្លាំងប្រដាប់អាវុធ ដើម្បីបង្កើនផលិតភាពការងារ និងពង្រឹងការផ្តល់សេវាសាធារណៈ, គិតគូរដល់ការបង្កើនប្រាក់សោធននិវត្តជូននិវត្តជន និងគិតគូរពីការចូលរួមចំណែករបស់រដ្ឋាភិបាលក្នុងរបបសន្តិសុខសង្គមជូនមន្ត្រីរាជការស៊ីវិល។ ទន្ទឹមនេះ ចំណាយមិនមែនបុគ្គលិកត្រូវបានគ្រោងប្រមាណ ៤៦,៣% នៃចំណាយចរន្តថវិការដ្ឋ ឬ ស្មើនឹង ៧,២៦% នៃ ផ.ស.ស.។ ចំណាយនេះនឹងត្រូវត្បិតត្បៀតឱ្យមានប្រសិទ្ធភាពបំផុត ព្រមទាំងតម្រង់ទៅលើសកម្មភាពកែទម្រង់នានា និងការអនុវត្តគោលនយោបាយសំខាន់ៗរបស់រាជរដ្ឋាភិបាល។ ដោយឡែក ចំណាយមូលធន ត្រូវបានគ្រោងបង្កើនដល់ប្រមាណជា ៩,០% នៃផ.ស.ស. (គ្រោងកើន ២១,២%)។
- ជារួម ចំណាយចរន្តថ្នាក់ជាតិសម្រាប់ឆ្នាំ ២០១៨ ត្រូវបានគ្រោងវិភាជទៅតាមវិស័យ ដូចខាងក្រោម÷
  - វិស័យរដ្ឋបាលទូទៅ ត្រូវបានគ្រោងប្រមាណ ២,១១% នៃផ.ស.ស. និងមានកំណើន ៤,៩% ធៀបនឹងច្បាប់ហិរញ្ញវត្ថុឆ្នាំ ២០១៧
  - វិស័យការពារជាតិ សន្តិសុខ និងសណ្តាប់ធ្នាប់សាធារណៈ ត្រូវបានគ្រោងប្រមាណ ៣,៨៩% នៃផ.ស.ស. និងមានកំណើន ១៥,៤% ធៀបនឹងច្បាប់ហិរញ្ញវត្ថុឆ្នាំ ២០១៧
  - វិស័យសង្គមកិច្ច ត្រូវបានគ្រោងប្រមាណ ៥,៤៥% នៃផ.ស.ស. និងមានកំណើន ១១,៥% ធៀបនឹងច្បាប់ហិរញ្ញវត្ថុឆ្នាំ ២០១៧
  - វិស័យសេដ្ឋកិច្ច ត្រូវបានគ្រោងប្រមាណ ១,៤៩% នៃផ.ស.ស. និងមានកំណើន ១២,៨% ធៀបនឹងច្បាប់ហិរញ្ញវត្ថុឆ្នាំ ២០១៧
  - ទន្ទឹមនេះដែរ ចំណាយមូលធន ត្រូវបានគ្រោងប្រមាណ ៩,០០% នៃផ.ស.ស. ក្នុងគោលដៅជួយទ្រទ្រង់ផលិតភាពក្នុងសេដ្ឋកិច្ច, អភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ និងជំរុញកំណើនសេដ្ឋកិច្ច។
- ឈរលើមូលដ្ឋានគម្រោងក្របខ័ណ្ឌចំណូល និងចំណាយខាងលើ អតិរេកថវិកាចរន្តសម្រាប់ឆ្នាំ ២០១៨ គ្រោងសម្រេចបានស្មើនឹងប្រមាណ ២,៩២% នៃ ផ.ស.ស. ចំណែកឧនភាពថវិកាសរុបត្រូវបានកំណត់ត្រឹម ៥,៩០% នៃ ផ.ស.ស.។ នៅក្នុងក្របខ័ណ្ឌហិរញ្ញវត្ថុសាធារណៈខាងលើនេះ, ដើម្បីធានាតុល្យភាពថវិកា រាជរដ្ឋាភិបាលគ្រោងនឹងប្រើប្រាស់ប្រាក់បញ្ញើរបស់រាជរដ្ឋាភិបាលចំនួនប្រមាណ ១,០% នៃ ផ.ស.ស. ត្រូវជា ៩៩៤ ៧៣៧ លានរៀល ក្នុងគោលបំណងដើម្បីបន្តគាំទ្រគម្រោងវិនិយោគលើហេដ្ឋារចនាសម្ព័ន្ធរូបវ័ន្ត សម្រាប់

ការធានាកំណើនសេដ្ឋកិច្ចប្រកបដោយចីរភាព, ការបន្តអនុវត្តកម្មវិធីកែទម្រង់សំខាន់ៗរបស់រាជរដ្ឋាភិបាល ដើម្បីបង្កើនភាពទាក់ទាញ និងភាពប្រកួតប្រជែងរបស់សេដ្ឋកិច្ចកម្ពុជា និងការដំឡើងបៀវត្សមន្ត្រីរាជការស៊ីវិល និងកងកម្លាំងប្រដាប់អាវុធគ្រប់ប្រភេទ តាមផែនការដែលបានគ្រោងទុក (សូមពិនិត្យក្របខ័ណ្ឌហិរញ្ញវត្ថុសាធារណៈឆ្នាំ ២០១៧-២០២០ មាននៅក្នុងឧបសម្ព័ន្ធ ២ គោរពភ្ជាប់មកជាមួយ)។

ដើម្បីធានាបាននូវការអនុវត្តតាមគោលដៅខាងលើ និងដោយផ្អែកលើស្ថានភាពម៉ាក្រូសេដ្ឋកិច្ច និងហិរញ្ញវត្ថុសាធារណៈឆ្នាំ ២០១៧ ការគ្រោងថវិកាឆ្នាំ ២០១៨ និងពេលខាងមុខ ត្រូវរៀបចំឡើងលើមូលដ្ឋានយុទ្ធសាស្ត្រ និងក្របខ័ណ្ឌនៃវិធានការ ដូចខាងក្រោម÷

**ក. ផ្នែកចំណូល**

**ក.១-ផ្នែកចំណូលពន្ធដារ**

ដើម្បីពង្រឹងប្រភពចំណូលសំខាន់ៗ ក៏ដូចជាឆ្លើយតបទៅនឹងបញ្ហាប្រឈមដែលអាចនឹងកើតមានក្នុងឆ្នាំ ២០១៨ វិធានការផ្នែកចំណូលពន្ធដារសម្រាប់បន្តអនុវត្តក្នុងឆ្នាំ ២០១៨ រួមមាន÷

- *បន្តពង្រឹងមុខងារប្រតិបត្តិការស្នូល ផ្តោតលើការចុះបញ្ជីអ្នកជាប់ពន្ធ, ការផ្តល់សេវាអ្នកជាប់ពន្ធ, ការចាត់ចែងលិខិតប្រកាស, ការធ្វើសវនកម្ម, ការស៊ើបអង្កេត, ការប្រមូលបំណុលពន្ធ និងបណ្តឹងតវ៉ា តាមរយៈ ÷*
  - ការធ្វើបច្ចុប្បន្នកម្មបញ្ជីអ្នកជាប់ពន្ធឱ្យបានទៀងទាត់ និងទាន់ពេលវេលា ជាពិសេសបន្តការងារលុបសហគ្រាសដែលបាត់ខ្លួនចេញពីបញ្ជី,
  - ការពង្រឹងការចុះបញ្ជីពន្ធដារចំពោះសហគ្រាសដែលមិនទាន់បានចុះបញ្ជីពន្ធដារ ដែលរកឃើញដោយការធ្វើអង្កេតសហគ្រាស និងផ្ទៀងផ្ទាត់ព័ត៌មានជាមួយស្ថាប័នផ្សេងៗ,
  - ការផ្តល់សេវាជូនអ្នកជាប់ពន្ធធំចំនួន ១៥០ សហគ្រាស តាមរយៈសិក្ខាសាលា និងការពិគ្រោះយោបល់ ទាក់ទងនឹងប្រព័ន្ធពន្ធដារ និងរដ្ឋបាលសារពើពន្ធ,
  - ការរៀបចំការដាក់លិខិតប្រកាស និងការបង់ប្រាក់ Online (E-Filing and E-Payment)
  - ការបន្តជំរុញការអនុវត្តកាតព្វកិច្ចផ្តល់របាយការណ៍ហិរញ្ញវត្ថុ ដែលធ្វើសវនកម្មដោយស្នងការគណនេយ្យ ឯករាជ្យ ដើម្បីពង្រឹងការគោរពច្បាប់ និងបន្ថយបន្ទុកសវនកម្ម,
  - ការពង្រឹងការធ្វើសវនកម្មលើវិស័យដែលមានសក្តានុពលមួយចំនួនដូចជា វិស័យនាំចេញ-នាំចូល វិស័យទេសចរណ៍ និងវិស័យសំណង់,
  - ការបន្តជ្រើសរើសសហគ្រាសដែលមានបុត្រសម្ព័ន្ធ (Group Companies) ជាអាទិភាពក្នុងការធ្វើសវនកម្ម ដោយសហការគ្នាជាក្រុម ដើម្បីរកឱ្យឃើញការគេចវេះពន្ធ និងការផ្ទេរថ្លៃ,
  - ការរៀបចំ និងដាក់ឱ្យអនុវត្តលិខិតបទដ្ឋានស្តីពីការផ្ទេរថ្លៃ (Transfer Pricing) ដើម្បីទប់ស្កាត់ការគេចវេះពន្ធ,

- ការពង្រឹងការអនុវត្តយ៉ាងម៉ឺងម៉ាត់នូវវិធានការតឹងទារបំណុលពន្ធ ដែលមានចែងក្នុងបទប្បញ្ញត្តិស្តីពីពន្ធដារ ដូចជាការរឹបអូស ឬការឃុំគ្រងទ្រព្យសម្បត្តិរបស់អ្នកជំពាក់បំណុលពន្ធ និងការប្តឹងអ្នកជំពាក់បំណុលពន្ធទៅតុលាការ។

• *បន្តការពង្រឹងមុខងារគាំទ្រ តាមរយៈ÷*
  - ការរៀបចំ និងដាក់ឱ្យអនុវត្តនូវផែនការអភិវឌ្ឍន៍ស្ថាប័ន,
  - ការពង្រឹងប្រព័ន្ធសុវត្ថិភាពបច្ចេកវិទ្យាព័ត៌មានឱ្យកាន់តែល្អប្រសើរ ដើម្បីឈានទៅការប្រើប្រាស់ប្រព័ន្ធគ្រប់គ្រងការងារសវនកម្ម ប្រព័ន្ធផ្ទៀងផ្ទាត់អាករលើតម្លៃបន្ថែម (VAT Cross-Checking) និងប្រព័ន្ធគ្រប់គ្រងបំណុលពន្ធ,
  - ការបង្កើតប្រព័ន្ធគ្រប់គ្រងអ្នកប្រើប្រាស់រួមតែមួយ (Core System-Single sign-on)។

**ក.២ ផ្នែកចំណូលគយ និងរដ្ឋាករ**

ក្នុងទិសដៅបន្តពង្រឹងប្រភពចំណូលសំខាន់ ក៏ដូចជាឆ្លើយតបទៅនឹងបញ្ហាប្រឈម ដែលនឹងអាចកើត-មានឡើងក្នុងឆ្នាំ ២០១៨ វិធានការជាក់លាក់សម្រាប់ផ្នែកចំណូលគយនិងរដ្ឋាករ ដែលត្រូវអនុវត្តក្នុងឆ្នាំ ២០១៨ រួមមាន៖

• *ការបន្តពង្រឹងការត្រួតពិនិត្យ និងបញ្ចេញទំនិញផ្តោតលើការប្រកាសគយ, ការកំណត់ និងធ្វើចំណាត់ថ្នាក់ហានិភ័យ និងសវនកម្មក្រោយពេលបញ្ចេញទំនិញពីគយ តាមរយៈ ÷*
  - ការបន្តលើកកម្ពស់អនុលោមភាព នៃការគ្រប់គ្រងចុះបញ្ជីទំនិញនាពេលនាំចូលមកដល់ដែនគយទាំងផ្លូវគោកនិងផ្លូវទឹក ព្រមទាំងការជំរុញឱ្យមានការជម្រះបញ្ជីពេញលេញជាមួយប្រតិវេទន៍គយ ដោយត្រូវផ្តោតជាសំខាន់លើទំនិញដែលមានវេទយិតភាពចំណូលខ្ពស់ ទំនិញកំណត់ពិសេសស្ថិតក្រោមប្រព័ន្ធត្រាពន្ធគយ និងទំនិញក្រោមរបបគយឆ្លងកាត់ប្រទេសជាប់ព្រំដែនរួចចូលកម្ពុជាតាមផ្លូវគោក,
  - ការចុះឃ្លាំមើលនិងវាយតម្លៃឱ្យបានទៀងទាត់របស់ថ្នាក់ដឹកនាំគយ និងសវនករមានសមត្ថកិច្ចនូវប្រសិទ្ធភាពនៃការអនុវត្តផែនការសកម្មភាពប្រចាំឆ្នាំរបស់អគ្គនាយកដ្ឋាន ជាពិសេសការអនុវត្តនីតិវិធីត្រួតពិនិត្យគយតាមអង្គភាពគយមូលដ្ឋានពាក់ព័ន្ធនឹងការប្រមូលចំណូលគយ,
  - ការលើកកម្ពស់ការយល់ដឹងនិងការទទួលខុសត្រូវរបស់មន្ត្រីគយ និងធុរជនលើនីតិវិធីគយ ជាពិសេសកាតព្វកិច្ចនានាពាក់ព័ន្ធនឹងការប្រកាស, ការបង់ពន្ធ, ការដឹកជញ្ជូនចែកចាយ និងការកាន់រក្សាទំនិញវេទយិត,
  - ការបន្តលើកកម្ពស់គុណភាពប្រព័ន្ធគ្រប់គ្រងហានិភ័យគយ និងប្រព័ន្ធព័ត៌មានសម្រាប់ជាមូលដ្ឋានក្នុងការបង្ក្រាបឬអនុវត្តយន្តការសវនកម្មតាមគ្រប់រូបភាព ព្រមទាំងការអនុវត្តនូវនីតិវិធីតាមផ្លូវតុលាការ លើជនសង្ស័យឬជនល្មើសដែលមិនរាងចាល,

- ការពង្រឹងប្រសិទ្ធភាពការងារត្រួតពិនិត្យរូបវ័ន្តលើទំនិញនៅយន្តការដើមទី ដោយអង្គភាពគយមូលដ្ឋានមានសមត្ថកិច្ចទាំងថ្នាក់ការិយាល័យ និងថ្នាក់សាខាគយឱ្យមានអនុលោមភាពពេញលេញជាមួយនីតិវិធីត្រួតពិនិត្យ ជាពិសេសការលើកកម្ពស់ការទទួលខុសត្រូវរបស់មន្ត្រីត្រួតពិនិត្យរូបវ័ន្តដោយភ្នែកទទេ និងតាមរយៈម៉ាស៊ីនស្កេន,
- ការដាក់ឱ្យអនុវត្តយន្តការផ្លាស់ប្តូរព័ត៌មានហានិភ័យផ្ទៃក្នុងគយ និងអន្តរស្ថាប័ន និងការលើកកម្ពស់កិច្ចសហការអន្តរស្ថាប័នទប់ស្កាត់និងបង្ក្រាបបទល្មើសគយ ជាពិសេសបទល្មើសគយជាក់ស្តែងពាក់ព័ន្ធនឹងការនាំចេញ-នាំចូលទំនិញតាមមាត់ច្រកទ្វេភាគី ឬច្រករបៀងខុសច្បាប់,
- ការបន្តលើកទឹកចិត្តឱ្យមានការចូលរួមរបស់ធុរជនល្អក្នុងការងារបង្ក្រាបបទល្មើសគយ ក្រោមក្របខ័ណ្ឌនៃយន្តការភាពជាដៃគូគយ និងវិស័យឯកជនតាមរូបភាពនៃការចូលរួមផ្តល់ព័ត៌មានព្រមទាំងបទពិសោធន៍ល្អៗក្នុងតំបន់,
- ការបន្តពង្រឹងប្រសិទ្ធភាពយន្តការសវនកម្មគយតាមរយៈ ការលើកកម្ពស់សមត្ថភាពអង្គភាពសវនកម្ម ការពង្រីកភាពគ្របដណ្តប់នៃយន្តការនេះដល់គ្រប់វិស័យធុរកិច្ច និងការប្រើប្រាស់ទិន្នន័យហានិភ័យដែលប្រមូលបានពីប្រភពក្នុងនិងក្រៅប្រទេស,

• *ការបន្តការពង្រឹងយន្តការគាំទ្រ តាមរយៈ÷*

- ការជំរុញអនុវត្តយន្តការសហការគយជាមួយស្ថាប័នមានសមត្ថកិច្ចផ្សេងទៀត ជាពិសេសជាមួយអគ្គនាយកដ្ឋានដឹកជញ្ជូននៃក្រសួងសាធារណការនិងដឹកជញ្ជូន ដើម្បីផ្ទៀងផ្ទាត់អនុលោមភាពពន្ធលើយានយន្តគ្រប់ប្រភេទនៅយន្តការកណ្តាលទី និងចុងទី ទាំងពេលនាំចូលសន្និធិ ពេលផ្គុំដំឡើង ពេលធ្វើផ្លាកលេខ និងពេលចរាចរចែកចាយតាមអាជីវកម្មដ្ឋាន ដោយផ្អែកលើប្រព័ន្ធទិន្នន័យ និងការកំណត់គម្បដ្ឋានច្បាស់លាស់ទាំងយានយន្តឯកជន, យានយន្តរដ្ឋ ព្រមទាំងយានយន្តក្រោមរបបបណ្តោះអាសន្នផ្សេងៗ,
- ការកសាង អនុវត្ត និងវាយតម្លៃការអនុវត្តផែនការសកម្មភាពឬគម្រោងលើកកម្ពស់ប្រសិទ្ធភាពគ្រប់គ្រង និងអភិវឌ្ឍអង្គភាពគយ ជាពិសេសលើ (១)-រចនាសម្ព័ន្ធគ្រប់គ្រង, (២)-សមត្ថភាពនិងសីលធម៌វិជ្ជាជីវៈមន្ត្រីគយ និង (៣)-ការបំពាក់មធ្យោបាយការងារទាំងមធ្យោបាយច្បាប់ និងមធ្យោបាយរូបវ័ន្តផ្សេងទៀតឱ្យបានសមស្របដូចជា មធ្យោបាយប្រដេញនឹងប្រព័ន្ធទំនាក់ទំនងគមនាគមន៍ ព្រមទាំងការអនុវត្តប្រព័ន្ធលើកទឹកចិត្តមន្ត្រីគយមានស្នាដៃ និងដាក់ទណ្ឌកម្មមន្ត្រីគយអសកម្ម,
- ការជំរុញពង្រឹងអនុលោមភាពអាជីវកម្មផលិតផលតេលសិលា និងថាមពលនាំចូលដោយបន្តផ្សព្វផ្សាយ និងអនុវត្តឱ្យបានកាន់តែពេញលេញតាមការកំណត់របស់រាជរដ្ឋាភិបាលជាធរមាន

ពាក់ព័ន្ធនឹងការធ្វើអាជីវកម្មនាំចូល សន្និធិ និងចរាចរចែកចាយផលិតផលតេលសិលា ជាពិសេស ការជំរុញអនុវត្តវិធានការបិទការនាំចូលផលិតផលតេលសិលាតាមផ្លូវគោក,

- ការបន្តពង្រីកភាពគ្របដណ្តប់និងមុខងារប្រព័ន្ធស្វ័យប្រវត្តិកម្មគយនានា ជាពិសេសការកសាងប្រព័ន្ធតភ្ជាប់ដោយមធ្យោបាយអេឡិចត្រូនិករវាងប្រព័ន្ធតម្លៃគិតពន្ធគយ ប្រព័ន្ធគ្រប់គ្រងហានិភ័យ ប្រព័ន្ធស្ថិតិគយ ជាមួយប្រព័ន្ធស្វ័យប្រវត្តិកម្មគយផ្សេងទៀត ក៏ដូចជាជាមួយអគ្គនាយកដ្ឋានពន្ធដារ,
- ការបន្តវាយតម្លៃជាប្រចាំនូវផលប៉ះពាល់លើចំណូលគយពីបញ្ហាប្រឈមនានា និងការធ្វើវិចារណកម្ម និងពិពិធកម្មគោលនយោបាយគយនានាសំដៅប៉ះប៉ូវចំណូលគយ ដែលបាត់បង់ពីបញ្ហាប្រឈមនីមួយៗឱ្យបានសមស្របនិងទាន់ពេលវេលា ជាពិសេស (១)- ការបន្តពិនិត្យលទ្ធភាពដំឡើងអត្រាអាករពិសេស (២)- ការពង្រឹងសមត្ថភាពបង្ក្រាបបទល្មើស និងការកាត់បន្ថយការលើកទឹកចិត្តពន្ធអាករហួសពីការអនុវត្តល្អក្នុងតំបន់ និង (៣)- ការចាត់វិធានការមុតស្រួចនានាបន្ថែមទៀត ដើម្បីរក្សាចីរភាពកំណើនចំណូលគយតាមគោលនយោបាយរាជរដ្ឋាភិបាល។

**ក.៣. ផ្នែកចំណូលមិនមែនសារពើពន្ធ**

ដើម្បីពង្រឹងប្រភពចំណូលសំខាន់ ក៏ដូចជាឆ្លើយតបទៅនឹងបញ្ហាប្រឈមសំខាន់ៗ ដែលនឹងអាចកើតមានឡើងក្នុងឆ្នាំ ២០១៨ វិធានការសម្រាប់អនុវត្តក្នុងឆ្នាំ ២០១៨ (មិនមែនជាវិធានការជាក់លាក់ក្នុងឆ្នាំទេ ប៉ុន្តែជាវិធានការប្រចាំគ្រាសំខាន់ៗ) ដែលត្រូវបន្តអនុវត្ត រួមមាន÷

- បន្តសម្របសម្រួលដំណើរការរបស់គណៈកម្មាធិការត្រួតពិនិត្យ និងវាយតម្លៃចំណូលមិនមែនសារពើពន្ធ,
- បន្តសម្របសម្រួលជាមួយថ្នាក់ដឹកនាំ និងមន្ត្រីបង្គោលតាមក្រសួង-ស្ថាប័នដែលទទួលខុសត្រូវក្នុងការតាមដាន កត់ត្រា កៀរគរចំណូល និងចាត់វិធានការតឹងទារបំណុល
- បន្តពង្រឹងប្រសិទ្ធភាពនៃការគ្រប់គ្រង ការកត់ត្រា និងការផ្តល់របាយការណ៍ចំណូលមិនមែនសារពើពន្ធឱ្យកាន់តែមានតម្លាភាព និងទាន់ពេលវេលា ដោយពង្រឹងការគ្រប់គ្រងស្ថាប័ន, ការទទួលខុសត្រូវច្បាស់លាស់, ការដាក់ទណ្ឌកម្ម, សវនកម្ម និងអធិការកិច្ច តាមរយៈអនុក្រឹត្យស្តីពីការគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ ដែលនឹងត្រូវបញ្ចប់ក្នុងពេលឆាប់ៗ,
- បន្តរកមុខចំណូលថ្មីៗ និងពង្រឹងការប្រមូលមុខចំណូលដែលមានស្រាប់ ដែលមិនប៉ះពាល់ដល់ជីវភាពរបស់ប្រជាជនទូទៅ ក្នុងនោះរួមមានការបន្តស្វែងយល់ពីបទពិសោធន៍ពីប្រទេសដទៃទៀត,
- បន្តពង្រឹងយន្តការគណៈកម្មការអន្តរក្រសួង ដើម្បីទប់ស្កាត់មិនឱ្យមានបំណុលថ្មី និងការតឹងទារបំណុល,
- បន្តជំរុញការរៀបចំប្រព័ន្ធគ្រប់គ្រងចំណូលមិនមែនសារពើពន្ធតាមប្រព័ន្ធព័ត៌មានវិទ្យា ដែលកំពុងរៀបចំដោយក្រុមការងាររបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងឈានទៅការបញ្ចប់ការរៀបចំប្រព័ន្ធ

ព័ត៌មានវិទ្យា ដើម្បីគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ,

- បន្តជំរុញការប្រើប្រាស់ប្រព័ន្ធធនាគារ ក្នុងការបង់ចំណូលទៅគណនីទោលរបស់រតនាគារជាតិឱ្យគ្រប់ចំនួន និងទាន់ពេលវេលា,
- ស្នើអាជ្ញាធរសវនកម្មជាតិធ្វើសវនកម្មលើការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ និងចំណូលមិនមែនសារពើពន្ធរបស់ក្រសួងស្ថាប័ន និងអង្គភាពរដ្ឋបាលថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ,
- ជំរុញអនុវត្ត និងកែលម្អស្តង់ដារសេវាសម្រាប់បង់ចំណូល ឱ្យមានភាពងាយស្រួល និងតម្លាភាព,
- បន្តពង្រឹងការប្រមូលកម្រៃពីសេវាដឹកអ្នកដំណើរតាមអាកាស ដែលបច្ចុប្បន្ន អគ្គនាយកដ្ឋានទ្រព្យរដ្ឋ និងចំណូលមិនមែនសារពើពន្ធ កំពុងសហការជាមួយរដ្ឋលេខាធិការដ្ឋានអាកាសចរណ៍ស៊ីវិល ដើម្បីបង្កើតកម្រៃ ៤ ដុល្លារអាមេរិក សម្រាប់អ្នកដំណើរក្នុងប្រទេស និង ៦ ដុល្លារអាមេរិក សម្រាប់អ្នកធ្វើដំណើរក្រៅប្រទេស,
- បន្តពង្រឹងប្រសិទ្ធភាពនៃការប្រមូលចំណូលពីដីសម្បទានសេដ្ឋកិច្ច ដោយផ្អែកលើគោលការណ៍កំណត់របស់រាជរដ្ឋាភិបាល,
- បន្តរៀបចំនិងបង្កើនប្រសិទ្ធភាពនៃការអនុវត្តលិខិតបទដ្ឋានគតិយុត្តិ ដើម្បីកៀរគរចំណូលពីវិស័យកាស៊ីណូ និងឆ្នោតឡូតូ,
- បង្កើនប្រសិទ្ធភាពនៃការគ្រប់គ្រងអាជីវកម្ម Online,
- ជំរុញការអនុម័តច្បាប់ស្តីពីការគ្រប់គ្រងរមណីយដ្ឋានសមាហរណល្បែងពាណិជ្ជកម្មឱ្យចេញនៅឆ្នាំ ២០១៨,
- បន្តកិច្ចសហការជាមួយក្រសួងមហាផ្ទៃ ដើម្បីបង្ក្រាបអាជីវកម្មល្បែងខុសច្បាប់។

## <u>២. ផ្នែកចំណាយ</u>

### ២.១- គោលនយោបាយអាទិភាពផ្នែកចំណាយ

ស្របតាមគោលដៅនៃស្ទួចនាករហិរញ្ញវត្ថុសាធារណៈដែលបានដាក់ចេញ រាជរដ្ឋាភិបាលបានកំណត់គោលនយោបាយហិរញ្ញវត្ថុសាធារណៈសម្រាប់ឆ្នាំ ២០១៨-២០២០ ដូចតទៅ៖

- បន្តធានាអនុវត្តគោលនយោបាយដើម្បីជំរុញកំណើន, ការងារ, សមធម៌ និងប្រសិទ្ធភាព ដើម្បីបន្តកាត់បន្ថយភាពក្រីក្ររបស់ប្រជាជន និងបែងចែកផ្លែផ្កាកំណើន ប្រកបដោយសមធម៌ដល់គ្រប់ស្រទាប់វណ្ណៈនៃប្រជាជន
- បន្តធានាសម្រេចឱ្យបាននូវកំណើនសេដ្ឋកិច្ចខ្ពស់ ប្រកបដោយបរិយាប័ន្ន និងចីរភាព ព្រមទាំងធានាបាននូវស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្នុងបរិការណ៍នៃអត្រាអតិផរណាទាប និងអត្រាប្តូរប្រាក់មានស្ថិរភាព,

- បន្តផ្តល់អាទិភាពដល់ការតម្លើងប្រាក់បៀវត្សជូនមន្ត្រីរាជការ និងកងកម្លាំងប្រដាប់អាវុធ ឆ្ពោះទៅសម្រេចគោលដៅច្រើនជាង ១ លានរៀល នៅឆ្នាំ ២០១៨ ដោយផ្សារភ្ជាប់ទៅនឹងការកែទម្រង់ប្រព័ន្ធបៀវត្ស និងការកែទម្រង់រដ្ឋបាលសាធារណៈ ជាពិសេសការអនុវត្តកម្មវិធីជាតិកំណែទម្រង់រដ្ឋបាលសាធារណៈ ២០១៥-២០១៨, ការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងការប្រយុទ្ធប្រឆាំងនឹងអំពើពុករលួយ,
- បន្តធានាអនុវត្តកម្មវិធីកែទម្រង់ចាំបាច់នានារបស់រាជរដ្ឋាភិបាលឱ្យមានលក្ខណៈស៊ីជម្រៅ និងទទួលបានលទ្ធផលជាផ្លែផ្កាជាក់ស្តែងជាបណ្តើរៗ រួមមានៈ ការកែទម្រង់កងកម្លាំងប្រដាប់អាវុធ, ការកែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ, ការកែទម្រង់ប្រព័ន្ធយុត្តិធម៌ និងតុលាការ, និងការគ្រប់គ្រងធនធានធម្មជាតិប្រកបដោយនិរន្តរភាព,
- បន្តជំរុញការអភិវឌ្ឍធនធានមនុស្ស តាមរយៈការលើកកម្ពស់គុណភាពអប់រំ និងអត្រាឡើងថ្នាក់របស់សិស្ស,
- ជំរុញការបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈ និងបច្ចេកទេសទាំងកម្រិតទាប មធ្យម និងខ្ពស់ ដើម្បីផ្គត់ផ្គង់ឱ្យបានគ្រប់គ្រាន់ទៅតាមតម្រូវការរបស់ធុរជន,
- បន្តលើកកម្ពស់សេវាសុខាភិបាលតាមរយៈការវិនិយោគបន្ថែមទាំងអគារមន្ទីរពេទ្យ, សម្ភារៈបរិក្ខារ និងសមត្ថភាពមន្ត្រីសុខាភិបាល,
- បន្តជំរុញការវិនិយោគលើហេដ្ឋារចនាសម្ព័ន្ធដឹកជញ្ជូន និងហេដ្ឋារចនាសម្ព័ន្ធចាំបាច់នានា សម្រាប់គាំទ្រដល់កំណើន និងការអភិវឌ្ឍ,
- បន្តជំរុញការអភិវឌ្ឍវិស័យកសិកម្ម ពិសេសផ្តោតទៅលើការផលិតពូជល្អ, បន្លែ, ការចិញ្ចឹមសត្វ និងវារីវប្បកម្ម, ការនាំអង្ករចេញ ព្រមទាំងផលិតកម្មកែច្នៃម្ហូបអាហារ,
- ពង្រឹង និងពង្រីកលំហថវិកា រួមទាំងយន្តការគ្រប់គ្រងវិបត្តិដើម្បីទប់ទល់វិបត្តិកលិយុគ និងហានិភ័យផ្សេងៗដែលអាចកើតមានឡើងជាយថាហេតុ,
- បន្តពង្រឹងការអនុវត្តគោលនយោបាយគ្រប់គ្រងបំណុលសាធារណៈ ឱ្យស្ថិតក្នុងកម្រិតមួយដែលអាចគ្រប់គ្រងបាន និងប្រកបដោយចីរភាព,
- បន្តពង្រឹងស្ថាប័នជាតិ និងប្រព័ន្ធអភិបាលកិច្ច ដើម្បីធានាប្រសិទ្ធភាព, គណនេយ្យភាព និងតម្លាភាព និងធានាបានសមធម៌សង្គម និងឱកាសស្មើគ្នា,
- លើកកម្ពស់គុណភាព និងប្រសិទ្ធភាពនៃសេវាសាធារណៈ ព្រមទាំងពង្រីកការទទួលបានការពេញចិត្តពីសេវាទាំងនេះ។

**២.២- វិធានការផ្នែកចំណាយ**

ដោយឈរលើមូលដ្ឋានការអនុវត្តចំណាយសាធារណៈកន្លងមក និងដើម្បីសម្រេចបានប្រសិទ្ធភាព និង

ស័ក្តិសិទ្ធភាពនៃវិត្ថារកម្មគោលនយោបាយចំណាយសាធារណៈ រាជរដ្ឋាភិបាលចាំបាច់ត្រូវអនុវត្តវិធានការ និង គោលការណ៍ជាក់លាក់មួយចំនួនក្នុងឆ្នាំ ២០១៨ ដែលរួមមាន÷

- បន្តការគិតគូរពីការរៀបចំថវិកាឱ្យកាន់តែមានលក្ខណៈផ្សារភ្ជាប់ទៅនឹងគោលនយោបាយអាទិភាពរបស់រាជរដ្ឋាភិបាល តាមរយៈការបង្កើនប្រសិទ្ធភាពនៃការវិភាជថវិកាឈរលើមូលដ្ឋានចាំបាច់, ជាក់ស្តែង និងចំទិសដៅ ពិសេសការពង្រឹងការអនុវត្តផែនការយុទ្ធសាស្ត្រថវិកា ស្របជាមួយនឹងការពង្រឹងប្រសិទ្ធភាពក្នុងការអនុវត្តថវិកា,
- ពង្រីកការដាក់ឱ្យអនុវត្តថវិកាកម្មវិធីពេញលេញ និងអង្គភាពថវិកាឱ្យបានគ្រប់ក្រសួង-ស្ថាប័នទាំងថ្នាក់ជាតិពីចំនួន ៣៦ ក្រសួង-ស្ថាប័ន ក្នុងឆ្នាំ ២០១៧ ឱ្យឡើងដល់ ៣៩ ក្រសួង-ស្ថាប័ន ក្នុងឆ្នាំ ២០១៨, និង ពង្រីកការសាកល្បងនៅថ្នាក់ក្រោមជាតិ,
- បន្តអនុវត្តគោលការណ៍បង្កើនបៀវត្សជូនមន្ត្រីរាជការស៊ីវិល និងកងកម្លាំងប្រដាប់អាវុធឱ្យទទួលបានច្រើនជាង ១ លានរៀល នៅឆ្នាំ ២០១៨ ក្នុងគោលដៅបង្កើនគុណភាព និងប្រសិទ្ធភាពនៃការផ្តល់សេវាសាធារណៈ ដោយឈរលើគោលការណ៍ប្រសិទ្ធភាព, សមធម៌, សង្គតិភាព, ចីរភាពថវិកា និងស្ថិរភាពសេដ្ឋកិច្ច,
- បន្តរក្សាអាទិភាព និង វិចារណកម្មនៃគោលនយោបាយចំណាយនៅក្នុងវិស័យអប់រំ, បណ្តុះបណ្តាលវិជ្ជាជីវៈ, ប្រព័ន្ធដឹកជញ្ជូន និងឡូជីស្ទីក, កសិកម្ម និងប្រព័ន្ធគាំពារសង្គម,
- បន្តធ្វើវិត្ថារកម្មគោលនយោបាយចំណាយ (រួមជាមួយការបន្តរឹតត្បិតចំណាយមិនចាំបាច់) ក្នុងស្មារតីគាំទ្រដល់ "គោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្ម" និងគាំទ្រដល់ការទ្រទ្រង់ចីរភាពកំណើនសេដ្ឋកិច្ចសម្រាប់រយៈពេលមធ្យម និងវែង តាមរយៈការបង្កើនការចំណាយវិនិយោគសាធារណៈលើការពង្រីកហេដ្ឋារចនាសម្ព័ន្ធរូបវ័ន្ត ដូចជា ផ្លូវថ្នល់, ផ្លូវដែក, កំពង់ផែ, ប្រព័ន្ធធារាសាស្ត្រស្រោចស្រព និងអគ្គិសនី។ល។ ដើម្បីផ្តល់ភាពងាយស្រួលដល់វិនិយោគិន, ពាណិជ្ជករ និងប្រជាជន។ បង្កើនការយកចិត្តទុកដាក់លើចំណាយថែទាំឱ្យមានប្រសិទ្ធភាព ក្នុងទិសដៅកែលម្អ និងពង្រឹងការថែទាំហេដ្ឋារចនាសម្ព័ន្ធរូបវ័ន្ត,
- បន្តផ្តោតការយកចិត្តទុកដាក់ និងបង្កើនការវិនិយោគសាធារណៈឱ្យចំវិស័យដែលផ្តល់ផលិតភាពខ្ពស់ ក្នុងគោលដៅទ្រទ្រង់កំណើនប្រកបដោយចីរភាព ដូចជា វិស័យកសិកម្ម វិស័យចំណីអាហារ និងវិស័យគាំទ្រដើម្បីជំរុញផលិតភាព, តម្លៃបន្ថែម និងជំរុញការកែច្នៃកសិផលសម្រាប់ការនាំចេញ, ការចិញ្ចឹមសត្វ និងវារីវប្បកម្ម តាមរយៈវិចារណកម្មគោលនយោបាយចំណាយក្នុងទិសដៅទទួលបានប្រសិទ្ធភាពខ្ពស់,
- បន្តជំរុញអនុវត្ត**កម្មវិធីសាច់ប្រាក់ពលកម្ម** (Cash For Work) ដែលជាកម្មវិធីដែលជួយស្តារ និងកសាងហេដ្ឋារចនាសម្ព័ន្ធជនបទ និងជាកម្មវិធីអន្តរាគមន៍ដោយត្រង់របស់រាជរដ្ឋាភិបាលក្នុងការបង្កើត

ការងារនៅទីជនបទ ដែលគាំទ្រដល់វិស័យជំនាញ ទប់ស្កាត់ការធ្វើចំណាកស្រុក, បង្កើនផលិតភាព និងលើកកម្ពស់ជីវភាពប្រជាជន នៅទីជនបទ,

- លើកកម្ពស់ប្រសិទ្ធភាពនៃប្រតិបត្តិការចំណាយ តាមរយៈការបង្កើនតម្លៃនៃលុយ ដោយផ្តោតការយកចិត្តទុកដាក់លើភាពសមស្របនៃថ្លៃ, បរិមាណ, គុណភាព និងភាពទាន់ពេលនៃថវិកាដែលបានចំណាយ ទាំងចំណាយចរន្ត (ចំណាយបុគ្គលិក និងមិនមែនបុគ្គលិក) និងចំណាយមូលធន,
- បន្តពង្រឹងការគ្រប់គ្រងចំណាយសាធារណៈ ជាពិសេសបន្តពង្រឹង និងជំរុញការកែលម្អការអនុវត្តថវិកា តាមរយៈការបន្តកាត់បន្ថយនីតិវិធីចំណាយ, ការបន្តពង្រឹងការគ្រប់គ្រងសាច់ប្រាក់, ការបន្តពង្រឹងការអនុវត្តកម្មវិធីចំណូល-ចំណាយប្រចាំត្រីមាស, ការបន្តត្រួតពិនិត្យការអនុវត្តថវិកាប្រចាំត្រីមាស និងឆមាស, ការបន្តពង្រឹងការត្រួតពិនិត្យផ្ទៃក្នុងដើម្បីបន្តពង្រឹងភាពជឿទុកចិត្តបាននៃថវិកាដែលសម្រេចបាន និងបន្តបង្កើនប្រសិទ្ធភាពគណនេយ្យភាពហិរញ្ញវត្ថុ និងជំហានបន្ទាប់ផ្សេងៗទៀត,
- គិតគូរឱ្យមានកញ្ចប់ថវិការត្រៀមបម្រុងសម្រាប់ដោះស្រាយតម្រូវការបន្ទាន់, ករណីតម្រូវការចំណាយចាំបាច់ភ្លាមៗរបស់រាជរដ្ឋាភិបាល, វិបត្តិផ្សេងៗ និងប្រធានស័ក្តិ,
- លើកកម្ពស់ប្រសិទ្ធភាពចំណាយវិនិយោគសាធារណៈពីគ្រប់ប្រភពហិរញ្ញប្បទាន ទាំងពីប្រភពថវិការដ្ឋ ប្រភពហិរញ្ញប្បទានក្រៅប្រទេស និងពីប្រភពថវិការបស់ដៃគូឯកជនតាមយន្តការភាពជាដៃគូរវាងរដ្ឋ និងវិស័យឯកជន ដោយត្រូវ÷
    - ការរៀបចំក្របខ័ណ្ឌ និងគោលការណ៍រួមសម្រាប់គ្រប់គ្រងការវិនិយោគសាធារណៈ ពីគ្រប់ប្រភពហិរញ្ញប្បទាន ដែលគ្រោងនឹងដាក់ឱ្យអនុវត្តដោយអនុក្រឹត្យនៅមុនដំណាច់ឆ្នាំ២០១៧,
    - ការរៀបចំគោលការណ៍ និងនីតិវិធីលម្អិតសម្រាប់គ្រប់គ្រងគម្រោងវិនិយោគសាធារណៈហិរញ្ញប្បទានពីប្រភពថវិកាជាតិ ដែលគ្រោងដាក់ឱ្យអនុវត្តដោយអនុក្រឹត្យនៅក្នុងឆ្នាំ២០១៨,
    - ការពិនិត្យ និងធ្វើបច្ចុប្បន្នកម្មលើនីតិវិធីរួមសម្រាប់គ្រប់គ្រងនិងអនុវត្តគម្រោងហិរញ្ញប្បទានពីដៃគូអភិវឌ្ឍន៍ ដែលគ្រោងនឹងដាក់ឱ្យអនុវត្តដោយអនុក្រឹត្យនៅក្នុងឆ្នាំ២០១៨, និង
    - ការរៀបចំក្របខ័ណ្ឌគតិយុត្ត យន្តការស្ថាប័ន និងនីតិវិធីប្រតិបត្តិការរួម សម្រាប់គ្រប់គ្រងការរៀបចំ និងអនុវត្តគម្រោងវិនិយោគសាធារណៈ តាមយន្តការភាពជាដៃគូរវាងរដ្ឋ និងវិស័យឯកជន ដែលគ្រោងនឹងដាក់ឱ្យអនុវត្តនៅឆ្នាំ២០១៨;
- បន្តអនុវត្តក្របខ័ណ្ឌគោលនយោបាយស្តីពីការគ្រប់គ្រងហានិភ័យបំណុល និងបន្តពង្រឹងបន្ថែមសមត្ថភាពស្ថាប័ន ដែលពាក់ព័ន្ធនឹងការគ្រប់គ្រងបំណុលសាធារណៈ ក្នុងគោលដៅបន្តរក្សាចីរភាពនៃការគ្រប់គ្រងបំណុល។

## ៣. រចនាសម្ព័ន្ធ និងគោលការណ៍នៃការរៀបចំផែនការយុទ្ធសាស្ត្រថវិកាឆ្នាំ ២០១៨-២០២០

ក្របខ័ណ្ឌគោលនយោបាយម៉ាក្រូសេដ្ឋកិច្ច និងគោលនយោបាយហិរញ្ញវត្ថុសាធារណៈ បានកំណត់

គោលដៅរួមនៃការប្រមូលចំណូល ដោយបានដាក់ចេញនូវវិធានការចាំបាច់ និងជាក់ស្តែងដែលត្រូវអនុវត្តក្នុងឆ្នាំ ដើម្បីសម្រេចគោលដៅទាំងនេះ និងបានកំណត់គោលដៅរួមនៃការអនុវត្តចំណាយ និងដាក់ចេញអាទិភាពគោលនយោបាយសំខាន់ៗ ដើម្បីសម្រេចគោលដៅរួមរបស់រាជរដ្ឋាភិបាល ដូចបានដាក់ចេញក្នុង **យុទ្ធសាស្ត្រចតុកោណ-ដំណាក់កាលទី៣ និងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ២០១៤-២០១៨**។ ដូច្នេះ ក្រសួង-ស្ថាប័ននីមួយៗ ត្រូវផ្អែកលើក្របខ័ណ្ឌគោលនយោបាយម៉ាក្រូសេដ្ឋកិច្ច និងគោលនយោបាយហិរញ្ញវត្ថុសាធារណៈដូចបានកំណត់ខាងលើ ដើម្បីរៀបចំផែនការយុទ្ធសាស្ត្រថវិការបស់ខ្លួន ឱ្យបានល្អត្រឹមត្រូវតាមទិសដៅនេះ និងជាក់ស្តែង។ ទន្ទឹមនេះ ដើម្បីជាមូលដ្ឋានសម្រាប់ក្រសួង-ស្ថាប័ន អាចរៀបចំផែនការយុទ្ធសាស្ត្រថវិកាប្រកបដោយប្រសិទ្ធភាព និងមានលក្ខណៈឯកភាពគ្នាទាំងរចនាសម្ព័ន្ធ និងទាំងខ្លឹមសារ ផែនការយុទ្ធសាស្ត្រថវិការបស់ក្រសួង-ស្ថាប័ននីមួយៗ ត្រូវរៀបចំតាមទម្រង់ដូចខាងក្រោម÷

- **ផ្នែកទី១: អំពីសេចក្តីផ្តើម**

ផែនការយុទ្ធសាស្ត្រថវិកាឆ្នាំ ២០១៨-២០២០ ត្រូវចាប់ផ្តើមដោយគូសរំលេចអំពីតួនាទី និងបេសកកម្មចម្បងៗរបស់ក្រសួង-ស្ថាប័ន, អំពីស្ថានភាពជាក់ស្តែងនៃការអនុវត្តផែនការយុទ្ធសាស្ត្រថវិកាឆ្នាំ ២០១៦-២០១៨ និងការប៉ាន់ស្មានស្ថានភាពនៃការអនុវត្តផែនការយុទ្ធសាស្ត្រថវិកាឆ្នាំ ២០១៧-២០១៩ ធៀបនឹងគោលដៅសូចនាករដែលបានកំណត់ និងលើកឡើងនូវបញ្ហាប្រឈមដែលត្រូវដោះស្រាយក្នុងឆ្នាំ ២០១៧ និងឆ្នាំខាងមុខ។ បន្ទាប់មកត្រូវបរិយាយរំលេចផងដែរអំពីវិធានការគោលនយោបាយសំខាន់ៗដែលក្រសួង-ស្ថាប័ន បានដាក់ចេញស្របតាមទិសដៅនៃ **យុទ្ធសាស្ត្រចតុកោណ-ដំណាក់កាលទី ៣** និង **ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ២០១៤-២០១៨** រួមទាំង គោលនយោបាយតាមវិស័យ និងអន្តរវិស័យ។ **សូមរៀបចំខ្លឹមសារនៃផ្នែកទី ១ នេះ ទៅតាមទម្រង់គំរូដែលភ្ជាប់ជាមួយសារាចរណែនាំនេះ។**

- **ផ្នែកទី២: អំពីគោលបំណងគោលនយោបាយ**

គោលបំណងគោលនយោបាយរបស់ក្រសួង-ស្ថាប័ន ត្រូវបានរៀបចំឡើងសម្រាប់ចក្ខុវិស័យរយៈពេលមធ្យម និងវែង (៣-៥ឆ្នាំ) ដោយផ្អែកលើគោលនយោបាយតាមវិស័យ និងអន្តរវិស័យ ដែលចែងក្នុងយុទ្ធសាស្ត្រចតុកោណ និងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ។ គោលបំណងគោលនយោបាយរបស់ក្រសួង-ស្ថាប័ននីមួយៗ មិនមែនជាកម្មវត្ថុនៃការធ្វើបច្ចុប្បន្នកម្មជារៀងរាល់ឆ្នាំទេ ប៉ុន្តែក្រសួង-ស្ថាប័នខ្លះ អាចត្រួតពិនិត្យឡើងវិញនូវគោលបំណងគោលនយោបាយដែលបានកំណត់ក្នុងផែនការយុទ្ធសាស្ត្រថវិកាឆ្នាំ ២០១៧-២០១៩ របស់ខ្លួនបាន ដើម្បីធានាថា គោលនយោបាយដែលបានកំណត់មានភាពត្រឹមត្រូវ គ្រប់ជ្រុងជ្រោយ ឆ្លើយតបបានកាន់តែច្បាស់លាស់ ទៅនឹងគោលនយោបាយតាមវិស័យរបស់ខ្លួន និងគោលដៅរួមរបស់រាជរដ្ឋាភិបាល។ ទន្ទឹមនេះ សូមបញ្ជាក់ ផងដែរថា *ក្រសួង-ស្ថាប័ននីមួយៗត្រូវមានគោលបំណងគោលនយោបាយមិនលើសពីពីរទេ*។ **សូមរៀបចំខ្លឹមសារ នៃផ្នែកទី ២ នេះទៅតាមទម្រង់គំរូដែលភ្ជាប់ជាមួយសារាចរណែនាំនេះ។**

• **ផ្នែកទី៣: អំពីកម្មវិធី**

ការរៀបចំកម្មវិធី (ក្រសួង-ស្ថាប័ន ដែលបាននិងកំពុងអនុវត្តថវិកាកម្មវិធី និង ក្រសួង-ស្ថាប័ន ដែលនឹងត្រូវអនុវត្តថវិកាកម្មវិធីចាប់ពីឆ្នាំ២០១៨) ត្រូវឆ្លើយតបនឹងគោលបំណងគោលនយោបាយដែលបានកំណត់ខាងលើ និងត្រូវបញ្ជាក់អំពីគោលបំណងនៃកម្មវិធីឱ្យច្បាស់លាស់ ដើម្បីឆ្លុះបញ្ចាំងឱ្យឃើញច្បាស់ថា ការអនុវត្តកម្មវិធីទាំងនោះ មានគោលដៅសម្រេចគោលបំណងគោលនយោបាយរបស់ក្រសួង-ស្ថាប័ន ដែលបានកំណត់។ ដូច្នេះ នៅក្នុងផ្នែកនេះ ក្រសួង-ស្ថាប័នដែលនឹងអនុវត្តថវិកាកម្មវិធីពេញលេញ និងអង្គភាពថវិកានៅឆ្នាំដំបូង ត្រូវបង្កើតឈ្មោះកម្មវិធី ព្រមជាមួយការរៀបរាប់និងពន្យល់អំពីគោលបំណងនៃកម្មវិធីទាំងនោះ។ ចំពោះក្រសួង-ស្ថាប័នដែលបាននិងកំពុងអនុវត្តថវិកាកម្មវិធីពេញលេញ និងអង្គភាពថវិកា ត្រូវធ្វើការពិនិត្យ និងកែលម្អឈ្មោះកម្មវិធីឱ្យកាន់តែល្អប្រសើរ ដោយឡែកក្រសួង-ស្ថាប័នដែលត្រៀមអនុវត្តថវិកាកម្មវិធីនៅឆ្នាំ ២០១៨ ត្រូវពិនិត្យ និង កែលម្អយុទ្ធសាស្ត្រអាទិភាពឱ្យបានច្បាស់លាស់ ដើម្បីចូលរួមចំណែកសម្រេចគោលនយោបាយអាទិភាពដែលបានដាក់ចេញនៅក្នុង **យុទ្ធសាស្ត្រចតុកោណ-ដំណាក់កាលទី ៣** និង **ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ២០១៤-២០១៨**។ ជាមួយគ្នានេះ ក្រសួង-ស្ថាប័ននីមួយៗ ត្រូវគិតគូរផងដែរដល់ការចូលរួមអនុវត្តការងារដែលមានចរិតជាអន្តរវិស័យ ដូចជា គោលនយោបាយអភិវឌ្ឍន៍ឧស្សាហកម្ម បញ្ហាយេនឌ័រ និងការប្រែប្រួលអាកាសធាតុ និងផលប៉ះពាល់ពីគ្រោះមហន្តរាយជាដើម។ សូមបញ្ជាក់ផងដែរថា ***ក្រសួង-ស្ថាប័ននីមួយៗ ត្រូវបង្កើតកម្មវិធីមិនឱ្យលើសពី ៥ ឡើយ*** ប៉ុន្តែចំពោះអនុកម្មវិធីអាចមានចំនួនសមស្របទៅតាមការចាំបាច់ ដែលបម្រើឱ្យគោលបំណងរួមនៃកម្មវិធីនីមួយៗ។

កម្មវិធី គឺជាឧបករណ៍ដែលបង្កើតឡើង ដើម្បីឱ្យអគ្គនាយកដ្ឋាន/នាយកដ្ឋាន ក្រោមឱវាទរបស់ក្រសួង-ស្ថាប័ន មន្ទីរជំនាញរាជធានី-ខេត្ត ព្រមទាំងគ្រឹះស្ថានសាធារណៈរដ្ឋបាលស្ថិតក្រោមក្រសួង-ស្ថាប័នសាមី ដាក់ចេញនូវអនុកម្មវិធី និងចង្កោមសកម្មភាព ព្រមទាំងជាមូលដ្ឋានសម្រាប់ការលើកគម្រោងថវិកាដើម្បីអនុវត្តកម្មវិធីទាំងនោះ ក្នុងគោលដៅសម្រេចគោលបំណងគោលនយោបាយដែលបានកំណត់នៅក្នុងផ្នែកទី ២។ គួរកត់សម្គាល់ថា ចង្កោមសកម្មភាព សំដៅលើសកម្មភាពចម្បងៗ ដែលអាចមានចំនួនសមស្របទៅតាមការចាំបាច់សម្រាប់បម្រើឱ្យគោលបំណងរួមនៃអនុកម្មវិធីនីមួយៗ ហើយចង្កោមសកម្មភាពមួយ អាចមានសកម្មភាពតូចៗមួយចំនួនដែលរួមចំណែកបង្កើតផលិតផលចេញ(Output) សម្រាប់ចង្កោមសកម្មភាពនោះ។

កម្មវិធី ត្រូវមានខ្លឹមសារទូលាយ និងមានលក្ខណៈគ្របដណ្តប់បានទាំងស្រុង គ្រប់តួនាទីភារកិច្ច និងបេសកកម្មរបស់ក្រសួង-ស្ថាប័ននីមួយៗ ព្រមទាំងមានលក្ខណៈសមាហរណកម្ម ដោយត្រូវគ្របដណ្តប់លើគម្រោង ឬ សកម្មភាពការងារទាំងអស់ ទាំងគម្រោង ឬសកម្មភាពការងារដែលហិរញ្ញប្បទានដោយថវិការដ្ឋ និងថវិកាហិរញ្ញប្បទានសហប្រតិបត្តិការ ទាំងថវិកាចរន្ត និងថវិកាមូលធន។ ជាមួយគ្នានេះ ក្រសួង-ស្ថាប័ន ត្រូវកំណត់អង្គភាពទទួលខុសត្រូវ ដែលហៅថា **អង្គភាពថវិកា** និងអ្នកគ្រប់គ្រងទៅតាមកម្រិតនៃរចនាសម្ព័ន្ធកម្មវិធី (កម្មវិធី អនុកម្មវិធី និង ចង្កោមសកម្មភាព)។

ទន្ទឹមនេះ ក្នុងក្របខ័ណ្ឌនៃការកែទម្រង់ប្រព័ន្ធថវិកា ក្រសួង-ស្ថាប័ននីមួយៗ ត្រូវកំណត់ភារកិច្ច វិសាលភាពការងារ និងក្របខ័ណ្ឌទទួលខុសត្រូវរបស់គ្រឹះស្ថានសាធារណៈរដ្ឋបាល និងមន្ទីរជំនាញរាជធានី-ខេត្ត ឱ្យច្បាស់លាស់នៅក្នុងរចនាសម្ព័ន្ធកម្មវិធី។ មន្ទីរជំនាញរាជធានី-ខេត្ត មិនចាំបាច់ត្រូវមានកម្មវិធីដោយឡែកទេ ព្រោះមន្ទីរជំនាញរាជធានី-ខេត្ត គឺជាដៃ ឬ ខ្សែបណ្តោយរបស់ក្រសួង នៅតាមរាជធានី-ខេត្ត ដែលមានភារកិច្ចចូលរួមចំណែកអនុវត្តបណ្តាកម្មវិធីរបស់ក្រសួង-ស្ថាប័ន។

ក្នុងន័យនេះ **ក្រសួង-ស្ថាប័ននីមួយៗ ត្រូវណែនាំមន្ទីរជំនាញរបស់ខ្លួននៅរាជធានី-ខេត្ត អំពីអនុកម្មវិធីរួមមួយនៅក្នុងកម្មវិធីមួយ ឬកម្មវិធីលើសពីមួយ ដោយផ្អែកលើមុខងារ វិសាលភាពការងារ និងលក្ខណៈដោយឡែកនៃគោលនយោបាយ និងសេវាសាធារណៈរបស់ក្រសួង-ស្ថាប័នរៀងៗខ្លួន ដើម្បីឱ្យមន្ទីរជំនាញរាជធានី-ខេត្ត របស់ខ្លួនដឹងច្បាស់អំពីទីតាំងនៃអនុកម្មវិធីរួមមួយនៅក្នុងកម្មវិធីមួយណា ឬនៅក្នុងគ្រប់កម្មវិធីទាំងអស់។ ជាទូទៅ មន្ទីរជំនាញមួយ អាចមានចង្កោមសកម្មភាពគាំទ្រគ្រប់កម្មវិធីរបស់ក្រសួង-ស្ថាប័ន ឬអាចមានចង្កោមសកម្មភាពគាំទ្រ ២ ទៅ ៣ អាស្រ័យទៅតាមតួនាទី និងភារកិច្ចរបស់មន្ទីរជំនាញរាជធានី-ខេត្តនៃក្រសួង-ស្ថាប័ននីមួយៗ។** ក្រសួង-ស្ថាប័ន មន្ទីរជំនាញរាជធានី-ខេត្ត និងគ្រឹះស្ថានសាធារណៈរដ្ឋបាល **ត្រូវរៀបចំផ្នែកទី ៣ នេះ ទៅតាមតារាងគំរូដែលភ្ជាប់ជាមួយ សារាចរណែនាំនេះ។**

- **ផ្នែកទី៤: សូចនាករ និងគោលដៅសូចនាករ នៃសមិទ្ធកម្ម ឬ លទ្ធផល**

គោលបំណងគោលនយោបាយ កម្មវិធី និងអនុកម្មនីមួយៗ ត្រូវមានសូចនាករ (Indicator) សម្រាប់វាស់វែងលទ្ធផល ឬ សមិទ្ធកម្ម ហើយត្រូវកំណត់គោលដៅ (Target) សូចនាករលទ្ធផលដែលចង់សម្រេចបានសម្រាប់ជាមូលដ្ឋាន នៃការត្រួតពិនិត្យតាមដាន និងវាយតម្លៃលទ្ធផលនៃការអនុវត្ត។ ក្នុងការកំណត់សូចនាករសម្រាប់ការវាស់វែង ក្រសួង-ស្ថាប័ននីមួយៗ ត្រូវកំណត់ទាំងសូចនាករធាតុចេញ ឬ លទ្ធផលក្នុងឆ្នាំ (Output) និងសូចនាករលទ្ធផល ឬ លទ្ធផលចុងក្រោយ (Outcome)។

សូចនាករធាតុចេញ ឬ លទ្ធផលក្នុងឆ្នាំ គឺជារង្វាស់ដែលបានជ្រើសរើសសម្រាប់វាស់លទ្ធផល/ សមិទ្ធកម្មនៃការអនុវត្ត កម្មវិធី អនុកម្មវិធី ចង្កោមសកម្មភាព ទៅតាមគោលដៅដែលបានកំណត់ក្នុងរយៈពេលជាក់លាក់មួយដែលមិនលើសពីមួយឆ្នាំ។ រីឯសូចនាករលទ្ធផល ឬ លទ្ធផលចុងក្រោយ គឺជារង្វាស់ដែលបានជ្រើសរើសសម្រាប់វាស់ លទ្ធផល/ សមិទ្ធកម្មចុងក្រោយនៃកម្មវិធី។

ក្រសួង-ស្ថាប័ននីមួយៗ អាចកែលម្អសូចនាករតាមកម្រិតនៃរចនាសម្ព័ន្ធកម្មវិធីនីមួយៗ តាមរយៈការបន្ថែមសូចនាករថ្មី និងកែសម្រួលសូចនាករចាស់ដែលបានកំណត់កន្លងមក។ ការជ្រើសរើសសូចនាករនីមួយៗ ត្រូវមានការពន្យល់ពីមូលហេតុឱ្យច្បាស់លាស់។ ចំពោះសូចនាករចាស់ ត្រូវបញ្ជាក់អំពីស្ថានភាពនៃការអនុវត្តឆ្នាំ ២០១៦ ការព្យាករស្ថានភាពនៃការអនុវត្តក្នុងឆ្នាំ ២០១៧ និងធ្វើបច្ចុប្បន្នភាពតាមការជាក់ស្តែង។

**កម្មវិធីនីមួយៗ អាចមានសូចនាករលទ្ធផលចុងក្រោយយ៉ាងច្រើនចំនួន ៣ និងសូចនាករលទ្ធផលក្នុងឆ្នាំមួយចំនួន** ដើម្បីជានាទូវការសម្រេចបានលទ្ធផលជាក់លាក់នៃការអនុវត្តកម្មវិធី។ ជារួម បន្ទាប់ពីការជ្រើសរើស

និងកំណត់បាននូវសូចនាករសមស្របរួចហើយ ចាំបាច់ត្រូវកំណត់គោលដៅនៃសូចនាករ ទាំងគោលដៅសូចនាករលទ្ធផលក្នុងឆ្នាំ និងគោលដៅសូចនាករលទ្ធផលចុងក្រោយ។ គោលដៅសូចនាករទាំងពីរប្រភេទនេះចាំបាច់ត្រូវឱ្យមានទំនាក់ទំនងគ្នា និងឆ្លើយតបគ្នាយ៉ាងមានប្រសិទ្ធភាព ដើម្បីធានានូវការសម្រេចបានលទ្ធផលនៃគោលបំណងគោលនយោបាយដែលបានកំណត់នៅក្នុងរយៈពេលជាក់លាក់មួយ។ គោលដៅសូចនាករលទ្ធផលក្នុងឆ្នាំមានលក្ខណៈជាបរិមាណ ឬ/និងជាគុណភាពប្រចាំឆ្នាំ ដែលជាសមិទ្ធកម្មនៃការអនុវត្ត កម្មវិធីនីមួយៗ។ រីឯគោលដៅសូចនាករលទ្ធផលចុងក្រោយ គឺជាគោលដៅសមិទ្ធកម្មចុងក្រោយជាបរិមាណឬ/និងជាគុណភាព ដែលជាលទ្ធផលបង្កើតឡើងដោយលទ្ធផលក្នុងឆ្នាំនៃការអនុវត្តកម្មវិធី នៅក្នុងរយៈពេល មធ្យមនិងវែង (លើសពី១ឆ្នាំ)។ ក្នុងការកំណត់គោលដៅសូចនាករ កត្តាចាំបាច់និងសំខាន់បំផុត គឺត្រូវដឹងអំពីស្ថានភាពបច្ចុប្បន្នរបស់សូចនាករទាំងនោះទើបអាចទៅកំណត់គោលដៅដែលចង់បាន ដើម្បីឱ្យឆ្លើយតបបាន ទៅនឹងគោលបំណងគោលនយោបាយដែលបានកំណត់ ហើយការកំណត់គោលដៅនេះ ចាំបាច់ត្រូវតែមាន ភាពសមស្របនិងប្រាកដនិយមដែលអាចអនុវត្តបាន។ ក្រសួង-ស្ថាប័ន មន្ទីរជំនាញរាជធានី-ខេត្ត និងគ្រឹះស្ថានសាធារណៈរដ្ឋបាល **ត្រូវរៀបចំខ្លឹមសារនៃផ្នែកទី ៤ នេះទៅតាមតារាងគំរូដែលភ្ជាប់ជាមួយសារាចរណែនាំនេះ។**

- **ផ្នែកទី៥: ការកំណត់ធនធានថវិកា**

ក្រសួង-ស្ថាប័ននីមួយៗ ត្រូវគ្រោងទាំងធនធានថវិកាជាតិ និងថវិកាហិរញ្ញប្បទានសហប្រតិបត្តិការសម្រាប់អនុវត្តកម្មវិធី សម្រាប់រយៈពេលបីឆ្នាំរំកិល ២០១៨-២០២០។

**ក-ការគ្រោងចំណូល**

ការគ្រោងចំណូល គឺជាការគ្រោងសម្រាប់រយៈពេល ៣ ឆ្នាំ ២០១៨-២០២០ ដោយរួមទាំងចំណូលថវិការដ្ឋដែលស្ថិតក្រោមការគ្រប់គ្រង និងប្រមូលផ្ទាល់ដោយក្រសួង-ស្ថាប័ន និងចំណូលដែលបានមកពីហិរញ្ញប្បទានសហប្រតិបត្តិការជាមួយដៃគូអភិវឌ្ឍ និង ប្រភពផ្សេងៗទៀត។ នៅក្នុងការគ្រោងចំណូល ក្រសួង-ស្ថាប័ន ដោយរួមទាំងមន្ទីរជំនាញរាជធានី-ខេត្ត និង គ្រឹះស្ថានសាធារណៈរដ្ឋបាល ត្រូវផ្តោតការយកចិត្តទុកដាក់លើចំណុចសំខាន់ៗ ដូចខាងក្រោម÷

- គោលដៅសូចនាករចំណូលនៃក្របខ័ណ្ឌគោលនយោបាយហិរញ្ញវត្ថុសាធារណៈ ដែលបានដាក់ចេញនៅក្នុងសារាចរនេះ
- ការវាយតម្លៃការអនុវត្តការប្រមូលចំណូលក្នុងឆ្នាំកន្លងទៅ និងការប៉ាន់ស្មានការអនុវត្តប្រមូលចំណូលក្នុងឆ្នាំកំពុងអនុវត្ត
- យុទ្ធសាស្ត្រកៀរគរចំណូលរយៈពេលមធ្យម ២០១៤-២០១៨ តាមរយៈការដាក់ចេញវិធានការជាក់ស្តែងបន្ថែមទៀតតាមក្រសួង-ស្ថាប័ននីមួយៗ ដើម្បីបង្កើនការប្រមូលចំណូល ដែលស្ថិតនៅក្រោមដែនសមត្ថកិច្ចរបស់ខ្លួន។

ក្រសួង-ស្ថាប័ន មន្ទីរជំនាញរាជធានី-ខេត្ត និងគ្រឹះស្ថានសាធារណៈរដ្ឋបាល ត្រូវរៀបចំផ្នែកនេះទៅតាម **តារាងគំរូដែលភ្ជាប់ជាមួយសារាចរណែនាំនេះ។** នៅក្នុងផ្នែកនេះ ប្រសិនបើក្រសួង-ស្ថាប័ន និងមន្ទីរជំនាញរាជធានី-ខេត្ត ដែលមិនមានប្រភពចំណូល គឺពុំតម្រូវឱ្យរៀបចំឡើយ ។

ទន្ទឹមនេះ ក្រសួង-ស្ថាប័ន និងមន្ទីរជំនាញរាជធានី-ខេត្ត ព្រមទាំងគ្រឹះស្ថានសាធារណៈរដ្ឋបាល ដែលមានប្រភពចំណូល គឺត្រូវរៀបចំដាក់ចេញវិធានការជាក់ស្តែងបន្ថែមទៀតតាមក្រសួង-ស្ថាប័ននីមួយៗ សម្រាប់ពង្រឹងការគ្រប់គ្រង និងការប្រមូលចំណូល ដែលស្ថិតនៅក្រោមដែនសមត្ថកិច្ចរបស់ខ្លួន។ *ផ្ទុយទៅវិញ ការគ្រោងចំណូលមិនអស់សក្តានុពលដែលមាន គឺជាកម្មវត្ថុនៃការរឹតត្បិតចំណាយ នៅក្នុងដំណាក់កាលចរចាកញ្ចប់ថវិកាប្រចាំឆ្នាំសម្រាប់ក្រសួង-ស្ថាប័ន ដែលមានភារកិច្ចប្រមូលចំណូល។*

**ខ-ការគ្រោងចំណាយថវិកា**

ការគ្រោងតម្រូវការចំណាយ គឺជាការគណនាចំណាយសម្រាប់រយៈពេល ៣ ឆ្នាំ ២០១៨-២០២០ ទៅតាមកម្មវិធីនីមួយៗ និងទៅតាមប្រភេទចំណាយ និងប្រភពធនធាន រួមទាំងថវិកាជាតិ និងថវិកាហិរញ្ញប្បទានសហប្រតិបត្តិការពីដៃគូអភិវឌ្ឍ។ ក្រសួង-ស្ថាប័ន មន្ទីរជំនាញរាជធានី-ខេត្ត និង គ្រឹះស្ថានសាធារណៈរដ្ឋបាល ត្រូវរៀបចំខ្លឹមសារនៃផ្នែកទី ៥ នេះ **តាមតារាងគំរូដែលភ្ជាប់ជាមួយសារាចរណែនាំនេះ។**

ក្នុងការគណនាអំពីតម្រូវការថវិកា ដើម្បីអនុវត្តកម្មវិធីនីមួយៗ ត្រូវផ្តោតការយកចិត្តទុកដាក់លើចំណុចសំខាន់ៗ ដូចខាងក្រោម÷

ទី១- ក្របខ័ណ្ឌគោលនយោបាយម៉ាក្រូសេដ្ឋកិច្ច និងគោលនយោបាយហិរញ្ញវត្ថុសាធារណៈ ដែលរាជរដ្ឋាភិបាលបានដាក់ចេញ តាមរយៈក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដែលរួមមានគោលដៅសូចនាករម៉ាក្រូសេដ្ឋកិច្ចសំខាន់ៗ ដូចជា កំណើនសេដ្ឋកិច្ចប្រចាំឆ្នាំ អត្រាអតិផរណាប្រចាំឆ្នាំ និងគោលដៅសូចនាករចំណាយព្រមជាមួយនឹងគោលនយោបាយអាទិភាពចំណាយទាំងផ្នែកចំណាយចរន្ត និង ចំណាយមូលធន ឬ ហៅថាចំណាយវិនិយោគ,

ទី២- ការវាយតម្លៃលើសមត្ថភាពរបស់ខ្លួន ក្នុងការអនុវត្តចំណាយក្នុងរយៈពេលកន្លងមក និងការប៉ាន់ស្មានសមត្ថភាពអនុវត្តចំណាយក្នុងឆ្នាំ ២០១៧ ដែលក្រសួង-ស្ថាប័ន មន្ទីរជំនាញរាជធានី-ខេត្ត និង គ្រឹះស្ថានសាធារណៈរដ្ឋបាលនីមួយៗបាននិងកំពុងអនុវត្ត,

ទី៣- ការកំណត់តម្រូវការថវិកាតាមឆ្នាំនីមួយៗ ត្រូវគណនាចំណាយប្រកបដោយសុក្រឹតភាពទៅតាមតម្រូវការជាក់ស្តែងនៃកម្មវិធីនីមួយៗ ដោយត្រូវគិតគូរឈរលើទិដ្ឋភាពបី ÷

- ផែនការសកម្មភាព ឬសកម្មភាពការងារដែលមានស្រាប់ដែលត្រូវបន្តអនុវត្ត ដើម្បីសម្រេចគោលនយោបាយរបស់ក្រសួង-ស្ថាប័ន រៀងៗខ្លួន,
- ផែនការសកម្មភាព ឬសកម្មភាពការងារដែលមានលក្ខណៈបញ្ចប់ត្រឹមមួយឆ្នាំ , និង

- ផែនការសកម្មភាព ឬសកម្មភាពការងារថ្មី ដើម្បីសម្រេចគោលនយោបាយរបស់ក្រសួង-ស្ថាប័ន រៀងៗខ្លួន។

ដូច្នេះ ផ្អែកលើគោលការណ៍ទាំងបីខាងលើនេះ គ្រប់ក្រសួង-ស្ថាប័ន មន្ទីរជំនាញរាជធានី-ខេត្ត និង គ្រឹះស្ថានសាធារណៈរដ្ឋបាលក្រោមឱវាទទាំងអស់ ត្រូវគ្រោងតម្រូវការចំណាយសម្រាប់ឆ្នាំ ២០១៨-២០២០ តាមគោលការណ៍នៃការកំណត់ពិដានកញ្ចប់ថវិកា ដូចខាងក្រោម៖

- **ចំណាយបន្ទុកបុគ្គលិក** (ជំពូក ៦៤) សម្រាប់គម្រោងចំណាយបន្ទុកបុគ្គលិកឆ្នាំ ២០១៨ ត្រូវគ្រោង តាមមូលដ្ឋាននៃក្របខ័ណ្ឌ និងកម្រិតបៀវត្សឆ្នាំ ២០១៧ គឺតាមតារាងប្រព័ន្ធប្រាក់បៀវត្ស នៃក្រសួង មុខងារសាធារណៈ និងតាមចំនួនមន្ត្រីរាជការដែលមានជាក់ស្តែងក្នុងឆ្នាំ ២០១៧ **ដោយដំឡើង បៀវត្សមូលដ្ឋានចំនួន ១២% ក្នុងមួយឆ្នាំ (គិតពីខែមករា ដល់ ធ្នូ)** ហើយចំនួនក្របខ័ណ្ឌថ្មីយ៉ាងច្រើន ត្រូវស្មើនឹងចំនួនមន្ត្រីរាជការដែលចូលនិវត្តន៍ ផ្ទេរចេញ ឬលាឈប់ពីក្របខ័ណ្ឌរដ្ឋ និងមរណភាព ដែលត្រូវកាត់ចេញពីអង្គភាពសាមី។ **ចំពោះការតម្លើងប្រាក់បំណាច់មុខងាររបស់មន្ត្រីរាជការស៊ីវិល និងកងកម្លាំងប្រដាប់អាវុធសម្រាប់ឆ្នាំ ២០១៨ នឹងត្រូវបានផ្តល់ទឹកប្រាក់បន្ថែមគិតពីខែ មេសា** ដោយផ្អែកលើកម្រិតនៃប្រាក់បំណាច់មុខងារនីមួយៗ ដោយកម្រិតក្រោម ៣០០ ០០០ រៀល ក្នុង ១ខែ បន្ថែមចំនួន ១០០ ០០០ រៀល និងបង្កើនរហូតដល់កម្រិតចាប់ពី ៨០០ ០០០រៀល ក្នុង ១ខែ បន្ថែមត្រឹម ៤០ ០០០ រៀល ។ ក្រសួងសេដ្ឋកិច្ចនិង ហិរញ្ញវត្ថុ និងក្រសួងមុខងារសាធារណៈ នឹង ចេញគោលការណ៍លម្អិតបន្ថែមសម្រាប់ការបន្ថែមជូនសម្រាប់កម្រិតចន្លោះពី ៣០០ ០០០រៀល ទៅ ៨០០ ០០០រៀល ក្នុងមួយខែ សម្រាប់ការរៀបចំថវិកាប្រចាំឆ្នាំនាពេលខាងមុខ។
- ដោយឡែក សម្រាប់គម្រោងចំណាយបន្ទុកបុគ្គលិកឆ្នាំ ២០១៩ និង ២០២០ ត្រូវគ្រោងក្នុងកម្រិត ក្របខ័ណ្ឌ និងកម្រិតបៀវត្សដែលបានគ្រោងសម្រាប់ឆ្នាំ ២០១៨ និងឆ្នាំ ២០១៩ រៀងៗគ្នា ហើយ ចំនួនក្របខ័ណ្ឌថ្មីយ៉ាងច្រើនត្រូវស្មើនឹងចំនួនមន្ត្រីរាជការដែលចូលនិវត្តន៍ ផ្ទេរចេញ ឬលាឈប់ពី ក្របខ័ណ្ឌរដ្ឋ និងមរណភាពដែលត្រូវកាត់ចេញពីអង្គភាពសាមី។
- **ចំណាយក្រៅបន្ទុកបុគ្គលិក** (ជំពូក៦០ ការទិញ, ជំពូក៦១ សេវាកម្ម, ជំពូក៦២ អត្ថប្រយោជន៍ សង្គម, ជំពូក៦៥ ឧបត្ថម្ភធន) ជាសរុបសម្រាប់ឆ្នាំ ២០១៨ ត្រូវគ្រោងស្មើនឹងកម្រិតឥណទាន អតិបរមានៃច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០១៧ ព្រោះអាទិភាពចំណាយឆ្នាំ ២០១៨ ដូចមានចែងក្នុងក្របខ័ណ្ឌគោលនយោបាយហិរញ្ញវត្ថុសាធារណៈ គឺផ្តោតជាសំខាន់លើការដំឡើង បៀវត្ស និងការវិនិយោគដើម្បីទ្រទ្រង់កំណើនសេដ្ឋកិច្ច។ ***ក្នុងន័យនេះ ក៏មិនមែនមានន័យថា កញ្ចប់ ថវិកាឆ្នាំ ២០១៨ នឹងទទួលបានស្មើឆ្នាំ ២០១៧ ដោយស្វ័យប្រវត្តិដែរ*** ព្រោះការគ្រោងចំណាយត្រូវ កាត់ចេញមុខចំណាយលើសកម្មភាពការងារដែលត្រូវបានបញ្ចប់ ហើយថវិកាដែលបានកាត់ចេញ នោះមិនមែនជាកម្មវត្ថុនៃការវិភាជឡើងវិញនោះទេ លុះត្រាតែផ្តល់ការពន្យល់ និងផ្តល់អំណះអំណាង

ឱ្យបានត្រឹមត្រូវ ជាក់លាក់ និងច្បាស់លាស់សម្រាប់សកម្មភាពការងារចាំបាច់ថ្មី ឬគោលនយោបាយថ្មី។ ដោយឡែកសម្រាប់ឆ្នាំ ២០១៩ និង ២០២០ ការគ្រោងចំណាយចរន្តអាចបង្កើន ក្នុងរង្វង់នៃកម្រិតអតិផរណា ធៀបនឹងកញ្ចប់ដែលបានគ្រោងសម្រាប់ឆ្នាំ ២០១៨ និងឆ្នាំ ២០១៩ រៀងៗគ្នា។ ហេតុនេះ រាល់ការកំណត់តម្រូវការចំណាយដែលធំ ថ្មី និង/ឬ ខ្ពស់ជាងគោលការណ៍ដែលបានចែងនេះ គឺត្រូវផ្តល់ឯកសារពាក់ព័ន្ធដែលមានការសិក្សា និងអំណះអំណាងឱ្យបានត្រឹមត្រូវជាក់លាក់ និងច្បាស់លាស់ នៅក្នុងដំណាក់កាលរៀបចំផែនការយុទ្ធសាស្ត្រថវិកានេះឱ្យហើយ មកក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ទើបអាចដាក់ជាកម្មវត្ថុនៃការពិចារណា និងពិភាក្សាចរចា នៅពេលរៀបចំកញ្ចប់ថវិកាប្រចាំឆ្នាំបាន។ ជារួម គុណភាពនៃផែនការយុទ្ធសាស្ត្រ គឺជាកម្មវត្ថុនៃការរឹតត្បិត ឬលើកទឹកចិត្ត ចំណាយនៅក្នុងដំណាក់កាលចរចាកញ្ចប់ថវិកាប្រចាំឆ្នាំ សម្រាប់គ្រប់ក្រសួង-ស្ថាប័ន មន្ទីរជំនាញរាជធានី-ខេត្ត និង គ្រឹះស្ថានសាធារណៈរដ្ឋបាល។

- **ចំណាយមូលធន/វិនិយោគដោយហិរញ្ញប្បទានថវិកាជាតិ** (ជំពូក២១) សម្រាប់ក្រសួងសាធារណការ និងដឹកជញ្ជូន, ក្រសួងអភិវឌ្ឍន៍ជនបទ, និង ក្រសួងធនធានទឹកនិងឧតុនិយម ត្រូវបន្តអនុវត្តតាមយន្តការគណៈកម្មការអន្តរក្រសួង ក្នុងការកំណត់អាទិភាពគម្រោង និងទំហំថវិកាសម្រាប់ឆ្នាំ ២០១៨ ដែលមានទំហំប្រហាក់ប្រហែលនឹងឆ្នាំ ២០១៧។ ដោយឡែក ក្រសួង-ស្ថាប័នពាក់ព័ន្ធផ្សេងទៀត ដែលមានតម្រូវការចំណាយវិនិយោគ ត្រូវសិក្សានិងលើកគម្រោងក្នុងកម្រិតទំហំថវិកាសមស្រប ដើម្បីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រៀបចំអាទិភាពភាវូបនីយកម្មគោរពសុំការសម្រេចរបស់ប្រមុខរាជរដ្ឋាភិបាលពិនិត្យ និងសម្រេច ទៅតាមលទ្ធភាពថវិកាក្នុងទំហំដ៏សមស្រប ប៉ុន្តែជាក់ស្តែង គឺអាស្រ័យលើលទ្ធភាពនៃថវិកាក្នុងដំណាក់កាលរៀបចំថវិកាប្រចាំឆ្នាំ។
- **ចំណាយមូលធន/វិនិយោគដោយហិរញ្ញប្បទានសហប្រតិបត្តិការដោយដៃគូអភិវឌ្ឍ** ក្រសួង-ស្ថាប័ន ដែលបាន និងកំពុងទទួលបានហិរញ្ញប្បទានសហប្រតិបត្តិការ ឬគ្រោងនឹងទទួលបានហិរញ្ញប្បទាន ស្របតាមកម្មវិធីវិនិយោគសាធារណៈបីឆ្នាំរំកិល (២០១៨-២០២០) ត្រូវគ្រោងឱ្យបានត្រឹមត្រូវទៅតាមកិច្ចព្រមព្រៀង ឬ អនុស្សារណៈនៃការយោគយល់គ្នា ឬ ការសន្យាតាមរយៈយន្តការផ្សេងៗ។

- **ផ្នែកទី៦: សេចក្តីសន្និដ្ឋាន**

ផ្នែកចុងក្រោយ គឺជាការសន្និដ្ឋានទៅលើការរៀបចំផែនការយុទ្ធសាស្ត្រថវិកាឆ្នាំ ២០១៨-២០២០ និងការលើកទិសដៅ និងវិធានការ ដើម្បីសម្រេចគោលដៅដែលបានកំណត់នៅក្នុងផែនការយុទ្ធសាស្ត្រថវិកាឆ្នាំ ២០១៨-២០២០។

## ៤. សេចក្តីសន្និដ្ឋាន

ផែនការយុទ្ធសាស្ត្រថវិកា គឺជាយន្តការមួយនៃដំណើការរៀបចំថវិកាប្រចាំឆ្នាំ ដែលបានដាក់ឱ្យអនុវត្តក្នុងក្របខ័ណ្ឌនៃការអនុវត្តកម្មវិធីកែទម្រង់ហិរញ្ញវត្ថុសាធារណៈ និងទិសដៅយុទ្ធសាស្ត្រនៃការកែទម្រង់ប្រព័ន្ធថវិកានៅកម្ពុជា ដែលក្រសួង-ស្ថាប័ននីមួយៗ ត្រូវរៀបចំឱ្យបានច្បាស់លាស់ ត្រឹមត្រូវ មានតម្លាភាព និង មានគណនេយ្យភាពដើម្បីអនុវត្តកម្មវិធីឬយុទ្ធសាស្ត្រអាទិភាព ក្នុងគោលដៅសម្រេចគោលបំណងគោលនយោបាយ របស់ក្រសួង-ស្ថាប័នរៀងៗខ្លួន និងដើម្បីចូលរួមចំណែកសម្រេចគោលនយោបាយរបស់រាជរដ្ឋាភិបាល ដែលបានដាក់ចេញក្នុង **យុទ្ធសាស្ត្រចតុកោណ-ដំណាក់កាលទី ៣ និងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ២០១៤-២០១៨។** ការរៀបចំផែនការយុទ្ធសាស្ត្រថវិកាគឺជាដំណាក់កាលទី១ នៃដំណើរការរៀបចំថវិកាប្រចាំឆ្នាំ ដែលក្រសួង-ស្ថាប័ននីមួយៗ មានលទ្ធភាពគ្រោងផែនការថវិកាសម្រាប់អនុវត្តកម្មវិធី ដោយផ្អែកលើក្របខ័ណ្ឌគោលនយោបាយម៉ាក្រូសេដ្ឋកិច្ច និងក្របខ័ណ្ឌគោលនយោបាយហិរញ្ញវត្ថុសាធារណៈ ដើម្បីបង្កើនការផ្សារភ្ជាប់ថវិកាទៅនឹង គោលនយោបាយរបស់ក្រសួង-ស្ថាប័ននីមួយៗ។

ការលើកកម្ពស់គុណភាព និងប្រសិទ្ធភាពនៃការរៀបចំផែនការយុទ្ធសាស្ត្រថវិកា ក្នុងក្របខ័ណ្ឌនៃការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ គឺជាវិធានការសំខាន់សម្រាប់លើកកម្ពស់ប្រសិទ្ធភាពនៃការរៀបចំថវិកា និងការបែងចែកធនធានថវិកា។ ជាវិធីសាស្ត្រជាក់ស្តែងមួយ ដើម្បីរៀបចំផែនការយុទ្ធសាស្ត្រថវិកាឆ្នាំ២០១៨-២០២០ ឱ្យបានសមស្រប ក្រសួង-ស្ថាប័ន មន្ទីរជំនាញរាជធានី-ខេត្ត និងគ្រឹះស្ថានសាធារណៈរដ្ឋបាលនីមួយៗ ត្រូវត្រួតពិនិត្យឡើងវិញ និងវាយតម្លៃការអនុវត្តកន្លងមក ដោយផ្អែកលើផែនការយុទ្ធសាស្ត្រថវិកាឆ្នាំ ២០១៧-២០១៩ របស់ខ្លួន ហើយរៀបចំកែសម្រួលទៅតាមការណែនាំនៃសារាចរនេះ។

*គ្រប់ក្រសួង-ស្ថាប័នទាំងអស់ ត្រូវបញ្ជូនផែនការយុទ្ធសាស្ត្រថវិកាសម្រាប់ឆ្នាំ២០១៨-២០២០ ដែលមានវិសាលភាពគ្របដណ្តប់ទាំងផែនការយុទ្ធសាស្ត្រថវិការបស់មន្ទីរជំនាញរាជធានី-ខេត្ត និងរបស់គ្រឹះស្ថានសាធារណៈរដ្ឋបាល មកក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុឱ្យបានមុនថ្ងៃទី ១២ ខែ ឧសភា ឆ្នាំ ២០១៧* ដើម្បីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុមានពេលវេលាគ្រប់គ្រាន់សម្រាប់ពិនិត្យនិងបូកសរុប និងស្នើសុំការបំភ្លឺបន្ថែមតាមការចាំបាច់ពីក្រសួង-ស្ថាប័ន និងមន្ទីរជំនាញរាជធានី-ខេត្ត និងគ្រឹះស្ថានសាធារណៈរដ្ឋបាល។ ដើម្បីសម្រួលដល់ដំណើរការ ពិនិត្យ និងបូកសរុបផែនការយុទ្ធសាស្ត្រថវិការបស់ក្រសួង-ស្ថាប័ននីមួយៗ *មន្ទីរជំនាញរាជធានី-ខេត្ត និងគ្រឹះស្ថានសាធារណៈរដ្ឋបាល ត្រូវបញ្ជូនផែនការយុទ្ធសាស្ត្រថវិកាមួយច្បាប់ទៅក្រសួង-ស្ថាប័នសាមី និងមួយច្បាប់មកក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ (នាយកដ្ឋានថវិកានីយកម្មនៃអគ្គនាយកដ្ឋានថវិកា) តាមពេលវេលា ដែលបានកំណត់ខាងលើ។* ប្រសិនបើក្រសួង-ស្ថាប័នមិនបានផ្តល់ផែនការយុទ្ធសាស្ត្រថវិកា តាមពេលវេលាកំណត់ខាងលើ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុត្រូវបានអនុញ្ញាតឱ្យស្នើការវិភាជកញ្ចប់ថវិកាប្រចាំឆ្នាំ ដោយផ្អែកលើមូលដ្ឋាននៃផែនការយុទ្ធសាស្ត្រថវិកាឆ្នាំចាស់ និងការអនុវត្តថវិកានៃឆ្នាំកន្លងទៅ។

ទទួលបានសារាចរណែនាំនេះ ក្រសួង-ស្ថាប័ន រួមទាំងមន្ទីរជំនាញរាជធានី-ខេត្ត និងគ្រឹះស្ថានសាធារណៈរដ្ឋបាលទាំងអស់ ត្រូវអនុវត្តឱ្យមានប្រសិទ្ធភាពខ្ពស់ និងឱ្យបានទាន់ឱសានវាទ។ ក្នុងករណីក្រសួង-ស្ថាប័ន និងមន្ទីរជំនាញរាជធានី-ខេត្ត និងគ្រឹះស្ថានសាធារណៈរដ្ឋបាល មានចំណុចណាមួយមិនច្បាស់លាស់ខាងផ្នែកបច្ចេកទេសរៀបចំ ត្រូវទាក់ទងមកក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ (អគ្គនាយកដ្ឋានថវិកា) ដើម្បីរៀបចំផែនការយុទ្ធសាស្ត្រថវិកាឆ្នាំ ២០១៨-២០២០ ឱ្យបានទាន់ពេលវេលាតាមកាលកំណត់ និងផ្ញើមកក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុឱ្យបានមុនថ្ងៃទី ១២ ខែ ឧសភា ឆ្នាំ ២០១៧។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១០ ខែមេសា ឆ្នាំ ២០១៧

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

<u>កន្លែងទទួល:</u>

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
  "ដើម្បីជូនជ្រាប"
-ទីស្តីការគណៈរដ្ឋមន្ត្រី
-ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
-រាជកិច្ច "ដើម្បីចុះផ្សាយ"
-គ្រប់ក្រសួង-ស្ថាប័ន
-គ្រប់អភិបាលនៃគណៈអភិបាលរាជធានី-ខេត្ត
-គ្រប់មន្ទីរជំនាញរាជធានី-ខេត្ត
  "ដើម្បីមុខការ"
-ឯកសារ-កាលប្បវត្តិ

| ឧបសម្ព័ន្ធ ១: សូចនាករម៉ាក្រូសេដ្ឋកិច្ចសំខាន់ៗ សម្រាប់ឆ្នាំ ២០១៦-២០២០ | | | | | |
|---|---|---|---|---|---|
| សូចនាករ | ២០១៦ប | ២០១៧ព | ២០១៨ព | ២០១៩ព | ២០២០ព |
| ផសស ថ្លៃបច្ចុប្បន្ន (ប៊ីលានរៀល) | 80,559 | 89,478 | 99,023 | 109,443 | 121,163 |
| ផសស សម្រាប់ម្នាក់ (ដុល្លារ) | 1,302 | 1,434 | 1,567 | 1,709 | 1,869 |
| កំណើន ផសស ពិត (%) | 7.0% | 7.0% | 7.0% | 7.0% | 7.1% |
| អត្រាបរិត្តិផរណា ផសស (%) | 1.8 | 1.8 | 1.9 | 1.9 | 2.0 |
| អត្រាអតិផរណា (%) | 3.0% | 3.8% | 3.5% | 3.3% | 3.4% |
| អត្រាប្តូរប្រាក់ (រៀល/ដុល្លារ) | 4,056 | 4,037 | 4,037 | 4,037 | 4,037 |
| | | | | | |
| ការនាំចេញ (%នៃ ផសស) | 46.5% | 47.2% | 47.4% | 48.2% | 49.2% |
| ការនាំចូល (%នៃ ផសស) | -63.7% | -62.5% | -62.4% | -62.8% | -62.8% |
| សមតុល្យពាណិជ្ជកម្ម (%នៃ ផសស) | -17.2% | -15.4% | -15.0% | -14.6% | -14.3% |
| សមតុល្យគណនីចរន្ត (%នៃ ផសស) | -8.3% | -7.9% | -8.5% | -8.3% | -7.4% |
| ទុនបម្រុងអន្តរជាតិ (លានដុល្លារ) | 6,731 | 7,538 | 7,853 | 9,079 | 9,697 |
| ចំនួនខែនៃការនាំចូល | 5.5 | 5.7 | 5.4 | 5.7 | 5.5 |

ឧបសម្ព័ន្ធ ២ : គ្រូបខ័ណ្ឌហិរញ្ញវត្ថុសាធារណៈ

ក. គ្រូបខ័ណ្ឌហិរញ្ញវត្ថុសាធារណៈ:២០១៦-២០១៨

*ផសស តាមថ្លៃថេរឆ្នាំ ២០១៦ (លទ្ធផលបឋម)* 80,559

*ផសស តាមថ្លៃថេរឆ្នាំ ២០១៧ (ប៉ាន់ស្មាន)* 89,478

*ផសស តាមថ្លៃថេរឆ្នាំ ២០១៨ (គម្រោង)* 99,023

*ឯកតា÷ ប៊ីលានរៀល*

| ចំណូល-ចំណាយ | ២០១៦ | | | | | ២០១៧ | | | | ២០១៨ | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | ច្បាប់ហិ | គណនា | %ច្បាប់ | %អនុ. ២០១៥ | %ផសស | ច្បាប់ហិ | កែសម្រួលព្យាករណ៍ចំណូល | ប្រែប្រួល កែ./ច្ប. | កែ.ព្យ % ផសស | គម្រោង | %កែ២០១៧ | %ច្បាប់ ២០១៧ | %ផសស |
| **ចំណូលសរុប** | **14,359** | **15,046** | **104.8%** | **118.3%** | **18.68%** | **16,617** | **16,773** | **156** | **18.75%** | **18,597** | **110.9%** | **111.9%** | **18.78%** |
| ចំណូលចរន្ត | 14,229 | 14,926 | 104.9% | 118.5% | 18.53% | 16,469 | 16,625 | 156 | 18.58% | 18,417 | 110.8% | 111.8% | 18.60% |
| ចំណូលមូលធន | 131 | 120 | 91.6% | 97.2% | 0.15% | 148 | 148 | 0 | 0.17% | 180 | 121.4% | 121.4% | 0.18% |
| **រដ្ឋបាលកណ្តាល** | | | | | | | | | | | | | |
| ***ចំណូលចរន្ត*** | ***13,407*** | ***14,125*** | ***105.4%*** | ***120.1%*** | ***17.53%*** | ***15,501*** | ***15,829*** | ***327*** | ***17.69%*** | ***17,490*** | ***110.5%*** | ***112.8%*** | ***17.66%*** |
| ចំណូលសារពើពន្ធ | 11,555 | 12,197 | 105.6% | 116.1% | 15.14% | 13,209 | 13,639 | 430 | 15.24% | 15,075 | 110.5% | 114.1% | 15.22% |
| ចំណូលមិនមែនសារពើពន្ធ | 1,852 | 1,927 | 104.1% | 153.7% | 2.39% | 2,292 | 2,189 | (103) | 2.45% | 2,415 | 110.3% | 105.3% | 2.44% |
| ***ចំណូលមូលធន*** | ***131*** | ***120*** | ***91.6%*** | ***97.2%*** | ***0.15%*** | ***148*** | ***148*** | ***0*** | ***0.17%*** | ***180*** | ***121.4%*** | ***121.4%*** | ***0.18%*** |
| **រាជធានី-ខេត្ត** | **821** | **802** | **97.6%** | **95.7%** | **1.00%** | **968** | **796** | **(172)** | **0.89%** | **927** | **116.4%** | **95.8%** | **0.94%** |
| ចំណូលសារពើពន្ធ | 778 | 754 | 97.0% | 99.1% | 0.94% | 926 | 742 | (185) | 0.83% | 867 | 116.9% | 93.5% | 0.88% |
| ចំណូលមិនមែនសារពើពន្ធ | 44 | 47 | 108.5% | 62.4% | 0.06% | 41 | 54 | 13 | 0.06% | 60 | 110.7% | 146.2% | 0.06% |
| **ចំណូលតាមអង្គភាព** | | | | | | | | | | | | | |
| អគ្គនាយកដ្ឋានពន្ធដារ | 5,685 | 6,002 | 105.6% | 115.8% | 7.45% | 6,826 | 6,770 | (57) | 7.57% | 7,612 | 112.4% | 111.5% | 7.69% |
| អគ្គនាយកដ្ឋានគយ និងរដ្ឋាករ | 6,648 | 6,949 | 104.5% | 119.8% | 8.63% | 7,309 | 7,611 | 302 | 8.51% | 8,330 | 109.4% | 114.0% | 8.41% |
| អគ្គនាយកដ្ឋានចំណូលផ្សេងៗ | 1,896 | 1,975 | 104.2% | 122.8% | 2.45% | 2,334 | 2,244 | (90) | 2.51% | 2,475 | 110.3% | 106.1% | 2.50% |
| **ចំណាយសរុប** | **18,284** | **17,448** | **95.4%** | **113.8%** | **21.66%** | **21,152** | **21,152** | **-** | **23.64%** | **24,439** | **115.5%** | **115.5%** | **24.68%** |
| ចំណាយចរន្ត | 11,825 | 11,762 | 99.5% | 123.2% | 14.60% | 13,799 | 13,799 | - | 15.42% | 15,527 | 112.5% | 112.5% | 15.68% |
| ចំណាយមូលធន | 6,458 | 5,687 | 88.1% | 98.3% | 7.06% | 7,353 | 7,353 | - | 8.22% | 8,912 | 121.2% | 121.2% | 9.00% |

ឧបសម្ព័ន្ធ ២ : ក្របខ័ណ្ឌហិរញ្ញវត្ថុសាធារណៈ

ក. ក្របខ័ណ្ឌហិរញ្ញវត្ថុសាធារណៈ:២០១៦-២០១៨

*ផសស តាមថ្លៃចរន្តឆ្នាំ ២០១៦ (លទ្ធផលបឋម) 80,559*

*ផសស តាមថ្លៃចរន្តឆ្នាំ ២០១៧ (ប៉ាន់ស្មាន) 89,478*

*ផសស តាមថ្លៃចរន្តឆ្នាំ ២០១៨ (គម្រោង) 99,023*

*ឯកតា÷ ប៊ីលានរៀល*

| ចំណូល-ចំណាយ | ២០១៦ | | | | | ២០១៧ | | | | ២០១៨ | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | ច្បាប់ហិ | គណនា | %ច្បាប់ | %អនុ. ២០១៥ | %ផសស | ច្បាប់ហិ | កែសម្រួលព្យាករណ៍ចំណូល | ប្រែប្រួល កែ./ច្ប. | កែ.ព្យ % ផសស | គម្រោង | %កែ២០១៧ | %ច្បាប់ ២០១៧ | %ផសស |
| **រដ្ឋបាលកណ្តាល** | | | | | | | | | | | | | |
| ***ចំណាយចរន្ត*** | ***11,157*** | ***11,093*** | ***99.4%*** | ***234.5%*** | ***13.77%*** | ***13,051*** | ***13,051*** | - | ***14.59%*** | ***14,813*** | ***113.5%*** | ***113.5%*** | ***14.96%*** |
| ***ចំណាយមូលធន*** | ***5,796*** | ***5,025*** | ***86.7%*** | ***95.5%*** | ***6.24%*** | ***6,468*** | ***6,468*** | - | ***7.23%*** | ***7,961*** | ***123.1%*** | ***123.1%*** | ***8.04%*** |
| -ដោយហិរញ្ញប្បទានក្នុងប្រទេស | 1,925 | 1,925 | 100.0% | 124.8% | 2.39% | 2,184 | 2,184 | - | 2.44% | 3,415 | 156.4% | 156.4% | 3.45% |
| -ដោយហិរញ្ញប្បទានក្រៅប្រទេស | 3,871 | 3,100 | 80.1% | 83.3% | 3.85% | 4,285 | 4,285 | - | 4.79% | 4,547 | 106.1% | 106.1% | 4.59% |
| **រាជធានីខេត្ត** | | | | | | | | | | | | | |
| ចំណាយចរន្ត | 1,182 | 1,192 | 100.9% | 108.7% | 1.48% | 1,387 | 1,387 | - | 1.55% | 1,452 | 104.7% | 104.7% | 1.47% |
| ចំណាយមូលធន | 153 | 153 | 100.0% | 79.7% | 0.19% | 219 | 219 | - | 0.24% | 213 | 97.3% | 97.3% | 0.22% |
| ***ឧបត្ថម្ភធនរាជធានី-ខេត្ត*** | ***513*** | ***523*** | ***102.0%*** | ***84.4%*** | ***0.65%*** | ***638*** | ***638*** | - | ***0.71%*** | ***738*** | ***115.6%*** | ***115.6%*** | ***0.75%*** |
| **តុល្យភាព** | | | | | | | | | | | | | |
| អតិរេកថវិកាចរន្ត | 2,403 | 3,165 | 131.7% | 103.7% | 3.93% | 2,670 | 2,826 | 156 | 3.16% | 2,890 | 102.3% | 108.3% | 2.92% |
| ឱនភាពសរុប | (3,924) | (2,402) | 61.2% | 92.0% | -2.98% | (4,535) | (4,379) | 156 | -4.89% | (5,842) | 133.4% | 128.8% | -5.90% |
| **ហិរញ្ញប្បទាននៃឱនភាព** | **3,924** | **2,402** | **61.2%** | **92.0%** | **2.98%** | **4,535** | **4,379** | **(156)** | **4.89%** | **5,842** | **133.4%** | **128.8%** | **5.90%** |
| ក្នុងប្រទេស | (659) | (1,427) | 216.6% | 90.3% | -1.77% | (666) | 0.5 | 666 | 0.00% | 257 | 55198.8% | -38.7% | 0.26% |
| ក្រៅប្រទេស | 4,583 | 3,830 | 83.6% | 91.4% | 4.75% | 5,200 | 5,200 | - | 5.81% | 5,584 | 107.4% | 107.4% | 5.64% |
| ទ្រទ្រង់ថវិការដោយដៃគូរអភិវឌ្ឍន៍ | 203 | 221 | 108.8% | 155.8% | 0.27% | 250 | 250 | - | 0.28% | 300 | 120.0% | 120.0% | 0.30% |
| មូលធនក្រៅប្រទេស | 3,871 | 3,100 | 80.1% | 83.3% | 3.85% | 4,285 | 4,285 | - | 4.79% | 4,547 | 106.1% | 106.1% | 4.59% |
| ការទូទាត់ប្រាក់កម្ចី | 509 | 509 | 100.0% | 154.3% | 0.63% | 666 | 666 | - | 0.74% | 737 | 110.8% | 110.8% | 0.74% |

ក្របខ័ណ្ឌចំណូល-ចំណាយរយៈពេលមធ្យម ២០១៧-២០២០ (*)

| ប៊ីលានរៀល | 2017 ច្បាប់ | 2017 កែតម្រូវព្យាករ | 2018 ព្យ. | 2019 ព្យ. | 2020 ព្យ. |
|---|---|---|---|---|---|
| *សមូតិកម្ម: % នៃចំណាយចរន្តសរុប* | *51.70%* | *51.70%* | *53.69%* | *53.69%* | *52.94%* |
| **ចំណូលក្នុងស្រុក** | **16,617** | **16,773** | **18,597** | **21,011** | **23,719** |
| ***ចំណូលចរន្តសរុប*** | ***16,469*** | ***16,625*** | ***18,417*** | ***20,821*** | ***23,527*** |
| អគ្គនាយកដ្ឋានគយ និងរដ្ឋាករ | 7,309 | 7,611 | 8,330 | 9,321 | 10,434 |
| អគ្គនាយកដ្ឋានពន្ធដារ | 6,826 | 6,770 | 7,612 | 8,798 | 10,133 |
| ចំណូលមិនមែនសារពើពន្ធសរុប | 2,334 | 2,244 | 2,475 | 2,702 | 2,959 |
| **ចំណាយសរុប** | **21,152** | **21,152** | **24,439** | **27,284** | **30,594** |
| ***ចំណាយចរន្តសរុប*** | ***13,799*** | ***13,799*** | ***15,527*** | ***17,215*** | ***19,204*** |
| បន្ទុកបុគ្គលិក | 7,134 | 7,134 | 8,337 | 9,243 | 10,167 |
| បន្ទុកមិនមែនបុគ្គលិក | 6,665 | 6,665 | 7,190 | 7,973 | 9,037 |
| **ចំណាយចរន្តថ្នាក់ជាតិ** | **13,051** | **13,051** | **14,813** | **16,391** | **18,255** |
| ក.វិស័យរដ្ឋបាលទូទៅ | 1,987 | 1,987 | 2,085 | 2,168 | 2,252 |
| ខ.វិស័យការពារជាតិ សន្តិសុខ និងសណ្តាប់ធ្នាប់ | 3,338 | 3,338 | 3,853 | 4,249 | 4,653 |
| គ.វិស័យសង្គមកិច្ច | 4,836 | 4,836 | 5,395 | 6,019 | 6,700 |
| ឃ.វិស័យសេដ្ឋកិច្ច | 1,306 | 1,306 | 1,473 | 1,638 | 1,763 |
| ង.ចំណាយផ្សេងៗ | 1,582 | 1,582 | 2,007 | 2,318 | 2,887 |
| ***ចំណាយមូលធនសរុប*** | ***7,353*** | ***7,353*** | ***8,912*** | ***10,069*** | ***11,389*** |
| **អតិរេកចរន្ត** | **2,670** | **2,826** | **2,890** | **3,606** | **4,322** |
| **ឱនភាព/អតិរេកសរុប** | **(4,535)** | **(4,379)** | **(5,842)** | **(6,274)** | **(6,875)** |
| | | | | | |
| **កំណើនប្រចាំឆ្នាំ** | | | | | |
| **ចំណូលក្នុងស្រុក** | | **11.5%** | **10.9%** | **13.0%** | **12.9%** |
| ***ចំណូលចរន្តសរុប*** | | ***11.4%*** | ***10.8%*** | ***13.1%*** | ***13.0%*** |
| អគ្គនាយកដ្ឋានគយ និងរដ្ឋាករ | | 9.5% | 9.4% | 11.9% | 11.9% |
| អគ្គនាយកដ្ឋានពន្ធដារ | | 12.8% | 12.4% | 15.6% | 15.2% |
| ចំណូលមិនមែនសារពើពន្ធសរុប | | 13.6% | 10.3% | 9.2% | 9.5% |
| **ចំណាយសរុប** | | **21.2%** | **15.5%** | **11.6%** | **12.1%** |
| ***ចំណាយចរន្តសរុប*** | | ***130.9%*** | ***12.5%*** | ***10.9%*** | ***11.6%*** |
| បន្ទុកបុគ្គលិក | | 23.3% | 16.9% | 10.9% | 10.0% |
| បន្ទុកមិនមែនបុគ្គលិក | | 15.2% | 7.9% | 10.9% | 13.4% |
| **ចំណាយចរន្តថ្នាក់ជាតិ** | | **11.0%** | **13.5%** | **10.7%** | **11.4%** |

ក្របខ័ណ្ឌចំណូល-ចំណាយរយៈពេលមធ្យម ២០១៧-២០២០ (*)

| ប៊ីលានរៀល | 2017 ច្បាប់ | 2017 កែតម្រូវព្យាករ | 2018 ព្យ. | 2019 ព្យ. | 2020 ព្យ. |
|---|---|---|---|---|---|
| ក.វិស័យរដ្ឋបាលទូទៅ | | 13.2% | 4.9% | 4.0% | 3.9% |
| ខ.វិស័យការពារជាតិ សន្តិសុខ និងសណ្តាប់ធ្នាប់ | | 19.5% | 15.4% | 10.3% | 9.5% |
| គ.វិស័យសង្គមកិច្ច | | 11.4% | 11.5% | 11.6% | 11.3% |
| ឃ.វិស័យសេដ្ឋកិច្ច | | 8.3% | 12.8% | 11.2% | 7.7% |
| ង.ចំណាយផ្សេងៗ | | 58.9% | 26.8% | 15.5% | 24.6% |
| *ចំណាយមូលធនសរុប* | | *29.3%* | *21.2%* | *13.0%* | *13.1%* |
| **អតិរេកចរន្ត** | | **-10.7%** | **2.3%** | **24.8%** | **19.9%** |
| **និនភាព/អតិរេកសរុប** | | **82.3%** | **33.4%** | **7.4%** | **9.6%** |
| | | | | | |
| ផលធៀបនៃផ.ស.ស | | | | | |
| **ចំណូលក្នុងស្រុក** | **18.57%** | **18.75%** | **18.78%** | **19.20%** | **19.58%** |
| *ចំណូលចរន្តសរុប* | *18.41%* | *18.58%* | *18.60%* | *19.02%* | *19.42%* |
| អគ្គនាយកដ្ឋានគយ និងរដ្ឋាករ | 8.17% | 8.51% | 8.41% | 8.52% | 8.61% |
| អគ្គនាយកដ្ឋានពន្ធដារ | 7.63% | 7.57% | 7.69% | 8.04% | 8.36% |
| ចំណូលមិនមែនសារពើពន្ធសរុប | 2.61% | 2.51% | 2.50% | 2.47% | 2.44% |
| **ចំណាយសរុប** | **23.64%** | **23.64%** | **24.68%** | **24.93%** | **25.25%** |
| *ចំណាយចរន្តសរុប* | *15.42%* | *15.42%* | *15.68%* | *15.73%* | *15.85%* |
| បន្ទុកបុគ្គលិក | 7.97% | 7.97% | 8.42% | 8.45% | 8.39% |
| បន្ទុកមិនមែនបុគ្គលិក | 7.45% | 7.45% | 7.26% | 7.28% | 7.46% |
| ចំណាយចរន្តថ្នាក់ជាតិ | 14.59% | 14.59% | 14.96% | 14.98% | 15.07% |
| ក.វិស័យរដ្ឋបាលទូទៅ | 2.22% | 2.22% | 2.11% | 1.98% | 1.86% |
| ខ.វិស័យការពារជាតិ សន្តិសុខ និងសណ្តាប់ធ្នាប់ | 3.73% | 3.73% | 3.89% | 3.88% | 3.84% |
| គ.វិស័យសង្គមកិច្ច | 5.41% | 5.41% | 5.45% | 5.50% | 5.53% |
| ឃ.វិស័យសេដ្ឋកិច្ច | 1.46% | 1.46% | 1.49% | 1.50% | 1.46% |
| ង.ចំណាយផ្សេងៗ | 1.77% | 1.77% | 2.03% | 2.12% | 2.38% |
| *ចំណាយមូលធនសរុប* | *8.22%* | *8.22%* | *9.00%* | *9.20%* | *9.40%* |
| **អតិរេកចរន្ត** | **2.98%** | **3.16%** | **2.92%** | **3.29%** | **3.57%** |
| **និនភាព/អតិរេកសរុប** | **-5.07%** | **-4.89%** | **-5.90%** | **-5.73%** | **-5.67%** |

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ :០៣៤.០៣ ន

# សារាចរណែនាំ

# ស្តីពី

# ការរៀបចំផែនការយុទ្ធសាស្រ្តថវិកាឆ្នាំ ២០១៨-២០២០

## ១. សេចក្តីផ្តើម

មាត្រា ៣៩ នៃច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ បានចែងថា ប្រតិទិនសម្រាប់ការរៀបចំសេចក្តីព្រាងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងប្រចាំឆ្នាំ ចែកជា ៣ ដំណាក់កាល÷ **ដំណាក់កាលទី ១** គឺការរៀបចំផែនការយុទ្ធសាស្រ្តថវិកា ចាប់ពីខែ មីនា ដល់ខែ ឧសភា, **ដំណាក់កាលទី ២** គឺការរៀបចំកញ្ចប់ថវិកា ចាប់ពីខែ មិថុនា ដល់ខែ កញ្ញា និង**ដំណាក់កាលទី ៣** គឺការអនុម័តថវិកា ចាប់ពីខែ តុលា ដល់ខែ ធ្នូ។ សម្រាប់ដំណាក់កាលទី ១ នេះ រាជរដ្ឋាភិបាល តាមរយៈក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ បានដាក់ចេញរួចហើយនូវក្របខ័ណ្ឌគោលនយោបាយម៉ាក្រូសេដ្ឋកិច្ច និងគោលនយោបាយហិរញ្ញវត្ថុសាធារណៈ សម្រាប់ការរៀបចំសេចក្តីព្រាងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០១៨ ដើម្បីឱ្យក្រសួង-ស្ថាប័ននីមួយៗ មានមូលដ្ឋានសម្រាប់ការរៀបចំផែនការយុទ្ធសាស្រ្តថវិកាឆ្នាំ ២០១៨-២០២០ និងការលើកគម្រោងថវិកាប្រចាំឆ្នាំ ២០១៨។ នៅជំហានបន្ទាប់នៃដំណាក់កាលទី ១ នេះ រាជរដ្ឋាភិបាលត្រូវដាក់ចេញសារាចរណែនាំស្តីពីការរៀបចំផែនការយុទ្ធសាស្រ្តថវិកាឆ្នាំ ២០១៨-២០២០ ដើម្បីផ្តល់គោលការណ៍ណែនាំថ្មីៗ និងមគ្គុទ្ទេសបច្ចេកទេសគន្លឹះ សម្រាប់ជាជំនួយដល់គ្រប់ក្រសួង-ស្ថាប័ន ក្នុងការធ្វើបច្ចុប្បន្នភាពផែនការយុទ្ធសាស្រ្តថវិកា ដែលជាផែនការថវិការយៈពេល បីឆ្នាំរំកិល ដែលក្រសួង-ស្ថាប័ន មន្ទីរជំនាញរាជធានី-ខេត្ត និងគ្រឹះស្ថានសាធារណៈរដ្ឋបាល ដែលស្ថិតក្រោមក្រសួង-ស្ថាប័ននីមួយៗ ត្រូវរៀបចំនៅដំណាក់កាលទីមួយ នៃដំណើរការរៀបចំគម្រោងថវិកាប្រចាំឆ្នាំ។ ដោយឡែក ចំពោះការរៀបចំផែនការយុទ្ធសាស្រ្តថវិកាសម្រាប់រដ្ឋបាលថ្នាក់ក្រោមជាតិ នឹងមានសារាចរណែនាំដោយឡែកមួយផ្សេងទៀត ស្របតាមច្បាប់ស្តីពីរបបហិរញ្ញវត្ថុ និងការគ្រប់គ្រងទ្រព្យសម្បត្តិរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ដែលត្រូវបានប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/ ០៦១១/០១១ ចុះថ្ងៃទី ១៧ ខែ មិថុនា ឆ្នាំ ២០១១។

ផែនការយុទ្ធសាស្រ្តថវិកា គឺជាឧបករណ៍មួយដ៏សំខាន់សម្រាប់÷ (១)-ផ្សារភ្ជាប់ថវិកាទៅនឹងគោលនយោបាយរបស់ក្រសួង-ស្ថាប័ន និងគោលនយោបាយរបស់រាជរដ្ឋាភិបាល, (២)-បង្កើនវិចារណកម្មអាទិភាពចំណាយឱ្យកាន់តែឆ្លើយតបទៅនឹងគោលនយោបាយរបស់ក្រសួង-ស្ថាប័ន, (៣)-ធានានិរន្តរភាពនៃការអនុវត្តកម្មវិធីរបស់ក្រសួង-

# ផែនការយុទ្ធសាស្ត្រថវិកាឆ្នាំ ២០១៨-២០២០

## ក្រសួង ស្ថាប័ន ....................

## I. សេចក្តីផ្តើម

..........................................................................................................................

១. រំលេចអំពីបេសកកម្ម និងភារកិច្ចចម្បងៗសម្រាប់ឆ្នាំ ២០១៨-២០២០ ក្នុងក្របខណ្ឌនៃតួនាទី និងភារកិច្ចរបស់ក្រសួង ស្ថាប័ន

..........................................................................................................................

..........................................................................................................................

..........................................................................................................................

២. បរិយាយអំពីលទ្ធផលសម្រេចបានក្នុងឆ្នាំ ២០១៦ (ធៀបសូចនាករដែលបានកំណត់)

..........................................................................................................................

..........................................................................................................................

..........................................................................................................................

៣. លើកអំពីបញ្ហាប្រឈម (ដែលត្រូវយកចិត្តទុកដាក់ក្នុងឆ្នាំ ២០១៧ និង ឆ្នាំខាងមុខ)

..........................................................................................................................

..........................................................................................................................

..........................................................................................................................

៤.លើកអំពីវិធានការគោលនយោបាយសម្រាប់រួមចំណែកអនុវត្តយុទ្ធសាស្ត្រចតុកោណ-ដំណាក់កាលទី៣ ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ២០១៤-២០១៨ រួមបញ្ចូលទាំងវិធានការគោលនយោបាយដែលមានចរិតតាមវិស័យ និងអន្តរវិស័យសម្រាប់ឆ្នាំ ២០១៨-២០២០

..........................................................................................................................

..........................................................................................................................

..........................................................................................................................

..........................................................................................................................